01355102

E1/464.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 28-Nov-2016, 14:10
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៤នាទី**

**សវនាការលើកទី៤៤៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម យ៉ា សុខន  ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែរន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ័ង

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក សេង លាង

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ស្រ៊ា រតនៈ

លោក ត្រាវីស ហ្វារ *(Mr. Travis FARR)*

លោក កូមេន គេននី *(Mr. Cóman Kenny)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោកស្រី ដូរីន ជិន *(Mrs. Doreen CHEN)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉ែន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្ល សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក កូមេន គេននី | អង់គ្លេស |
| លោកស្រី ដូរីន ជិន | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក យស ផល (2-TCCP-232) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី ÷ យស ផល** (2-TCCP-232)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី .................... ទំព័រ ៧
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្ដើមពី .................... ទំព័រ ៨
សួរដោយលោក កូមេន គេននី ផ្ដើមពី.................... ទំព័រ ២៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:១២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម 2-TCCP-232 ដោយសារតែស្ថានភាពសុខភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-264 មិនទាន់បានប្រសើរឡើង តាមលិខិតរបស់វេជ្ជបណ្ឌិតចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ បានផ្តល់អនុសាសន៍ថា ដើមបណ្តឹងរូបនេះមិនអាចចូលរួមសវនាការបានទេ ជំងឺគាត់ត្រូវការព្យាបាលមួយរយៈពេលបន្តទៀត។

ក្រឡាបញ្ជីសវនាការកញ្ញា ស៊ីហ៊ាង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលទាំងឡាយដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

អញ្ជើញ!

[០៩:០៥:២៩]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCCP-232 ហើយគាត់មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ នៅថ្ងៃនេះ មិនមានសាក្សីបម្រុងទេ លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណកញ្ញា ស៊ីហ៊ាង។

ជាដំបូង អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះមិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦។ មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៧:០៥]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យ ព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅអ.វ.ត.ក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា ថ្ងៃនេះមានអាការៈឈឺចង្កេះជាប្រចាំ ហើយឈឺកាន់តែខ្លាំងនៅពេលអង្គុយយូរ ធ្វើវិលមុខ និងបានផ្តល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃ។

[០៩:០៨:០០]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

យើងបានទទួលបានព័ត៌មានថា មេធាវី ខៀវ សំផន -- និងទទួលបានតាមរយៈអ៊ីម៉ែលមុននេះបន្តិចថា ខ្លួនមានបំណងធ្វើសារណាទាក់ទងទៅនឹងឯកសារលេខ E2327/4/5 របស់អង្គជំនុំជម្រះសាលាដំបូងដែលចេញកាលពីម្សិលមិញ។ អង្គជំនុំជម្រះសូមអនុញ្ញាតឲ្យលោកស្រីមេធាវីធ្វើសារណា។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សូមអញ្ជើញលោកមេធាវី!

[០៩:០៩:១៨]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំសូមធ្វើការកត់សម្គាល់ និងសំណើដោយខ្លី។ កាលពីម្សិលមិញ យើងបានទទួលអនុស្សរណៈរបស់អង្គជំនុំជម្រះ គឺ E327/4/5 ដែលបញ្ជាក់ថា <អង្គជំនុំជម្រះ>ទទួលបានឯកសារមួយចំនួនពីសាលវិទ្យាល័យអាមេរិក ហើយនិងជាបណ្ណសារវៀតណាម ក្រោយពីមានសំណើកាលពី៣ឆ្នាំមុន ហើយអង្គជំនុំជម្រះបានបង្គាប់ឲ្យយើងខ្ញុំធ្វើសេចក្ដីកត់សម្គាល់ទៅលើការទទួលយកឯកសារនេះ <មុន>ថ្ងៃទី៣០ ខែសីហា គឺមានរយៈពេល៥ថ្ងៃ ហើយអង្គជំនុំជម្រះបញ្ជាក់ថាឯកសារផ្សេងទៀតកំពុងតែបកប្រែ ហើយនិងត្រូវធ្វើការកត់សម្គាល់ផ្សេងទៀត<មុន>ថ្ងៃទី១៥ ខែកញ្ញា។ <សំណើទី១ របស់ខ្ញុំគឺនៅថ្ងៃទី៣០ ខែសីហា> ទោះបីជាអង្គជំនុំជម្រះចង់ទៅមុខឲ្យបានឆាប់រហ័ស ពីព្រោះថាអ្វីៗគឺទៅមុខលឿន ក៏ប៉ុន្តែរហូតទៅដល់ថ្ងៃ៣០ហ្នឹង គឺវាពិបាកណាស់ យើងពិបាកធ្វើសារណាពាក់ព័ន្ធទៅនឹងសំណើនេះណាស់។ ពេលវេលានេះវាខ្លីពេក ពីព្រោះថាយើងមានការងារដែលត្រូវធ្វើផ្សេងទៀត គឺជារៀងរាល់ថ្ងៃនេះគឺយើងតែងតែមានសាក្សីម្នាក់ជារៀងរាល់ថ្ងៃ ដែលយើងត្រូវសួរដេញដោល ហើយយើងក៏ត្រូវរៀបចំខ្លួនសម្រាប់ការសួរដេញដោលអ្នកជំនាញ ដែរ។ ដូច្នេះ កាលកំណត់រហូតដល់ថ្ងៃ៣០ ខែសីហា នេះគឺយើងមិនអាចទទួលយកបានទេ ដូច្នេះយើងខ្ញុំសូមឲ្យអង្គជំនុំជម្រះពិនិត្យមើលកាលកំណត់នេះឡើងវិញ តើអាចកែប្រែបានដែរឬទេ? ពីព្រោះថា បើយើងនិយាយអំពីភាពទទួលយកបាននៃឯកសារហ្នឹង គឺថាមតិកត់សម្គាល់របស់យើង គឺវាមានលក្ខណៈដូចគ្នា <ផ្អែកទៅលើអ្វីដែលយើងអាន>។ ដូច្នេះ ឯកសារបួនហ្នឹងជាភាសាបារាំង ហើយមានឯកសារមួយចំនួនហ្នឹងគឺត្រូវបកប្រែ អ៊ីចឹងវាពិបាកដែរនៅពេលដែលយើងធ្វើការទៅលើឯកសារបកប្រែដែលមិនមែនជាឯកសារដើមនុ៎ង។

[០៩:១១:៤៦]

ដូច្នេះ ខ្ញុំសូមបញ្ជាក់ជាថ្មីម្ដងទៀត គឺកាលកំណត់រហូតទៅដល់ថ្ងៃទី៣០ ខែសីហា នេះគឺយើងមិនអាចធ្វើបានទេ ដូច្នេះយើងខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះមេត្តាពិនិត្យ ឬពិចារណាលើកាលកំណត់នេះឡើងវិញ។ យើង<ខ្ញុំឆ្លៀតឱកាសនេះ ប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការនិយាយ។ អង្គជំនុំជម្រះបានប្រាប់យើងខ្ញុំ> កាលពីកិច្ចប្រជុំរៀបចំសវនាការរួចមកហើយ យើងដឹងថាកាលណោះអង្គជំនុំជម្រះមិនជំទាស់ទៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នឹងកាលកំណត់ថ្ងៃទី៣០ ខែកញ្ញា <ដើម្បីដោះស្រាយរាល់សំណើតាមវិធាន ៨៧(៤)ទាំងអស់ ដែលបានធ្វើមុនថ្ងៃទី០១ ខែកញ្ញា> ដែលបានដាក់បង្ហាញដោយសហព្រះរាជអាជ្ញា<> ក៏ប៉ុន្តែសេចក្តីសម្រេចនុំងមិនទាន់បានចេញជាផ្លូវការនៅឡើយទេ។ ដូច្នេះ យើងខ្ញុំចង់ដឹងថា តើសេចក្តីសម្រេចនុំងនឹងចេញឆាប់ៗនេះដែរឬទេ ដើម្បីឲ្យយើងអាចរៀបចំខ្លួន ហើយនិងបែងចែកការងារគ្នាធ្វើ។ <ដូច្នេះ មាន> ចំណុច<ពីរ>ដែលយើងចង់លើកឡើង ហើយខ្ញុំសូមរំឭកថា នៅក្នុងការបែងចែកការងារគ្នាហ្នឹងគឺថា <មានបញ្ហាខ្លះអាចធ្វើបានដោយអ្នកដែលមិនចូលរួមក្នុង>សវនាការ<>ប៉ុន្តែយើងជាមេធាវីទាំងពីរនេះ គឺយើងតែងតែនៅក្នុងសវនាការរហូត <ហើយមានបញ្ហាជាក់លាក់ជាច្រើនដែលយើងមិនអាចធ្វើបាន> ។ ដូច្នេះ អង្គជំនុំជម្រះគួរតែពិចារណាទៅលើចំណុចនេះផង ពីព្រោះថាយើងមានគ្នាតិច អ៊ីចឹងវាពិបាកក្នុងការបែងចែកការងារគ្នាណាស់។ នេះជាសំណើដែលយើងខ្ញុំសូមដាក់ជូនអង្គជំនុំជម្រះនៅព្រឹកនេះ។

[០៩:១៣:១៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលេ៖**

សូមគោរពលោកប្រធាន លោក លោកស្រី ចៅក្រម ជម្រាបសួរភាគីទាំងអស់។ យើងខ្ញុំមិនមានអ្វីច្រើនដែលត្រូវលើកឡើងទេ យើងគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងសំណើសុំពេលវេលាសម្រាប់ការធ្វើការកត់សម្គាល់ទៅលើឯកសារដែលបានមកពីវៀតណាមនោះ។ ទោះបីជាថ្ងៃ ៣០ កញ្ញា ឬ ៣០ សីហា ឬក៏ថ្ងៃទី១៥ កញ្ញា ក៏ដោយយើងមិនជំទាស់អ្វីទេ គឺយើងខ្ញុំគោរពទៅតាមអង្គជំនុំជម្រះសម្រេច។ ក៏ប៉ុន្តែខ្ញុំសូមបញ្ជាក់ផងដែរថា <វាប្រហែលជាចាំបាច់ក្នុងការ>ពិនិត្យមើលតារាងដែលបង្ហាញអំពីឯកសារផ្សេងៗដែលបានដាក់ភ្ជាប់មក <ព្រោះថា តាមដែលខ្ញុំដឹង>នោះមានឯកសារមួយចំនួន វាមិនត្រូវគ្នាទៅនឹងឯកសារដែលបានដាក់ភ្ជាប់ជូន។ ដូច្នេះ យើងខ្ញុំមានការលំបាក គឺជាពិសេសឯកសារលេខ៥ គឺ E327/4/5.1។ <>បញ្ជី<នៅក្នុងតារាង> ឯកសារទី៥ ហ្នឹងដូចជាមិនត្រូវទៅនឹង ERN ជាភាសាអង់គ្លេស ដែលបានដាក់ភ្ជាប់ជូន គឺចំណងជើងហ្នឹងដូចជាវាមិនត្រូវគ្នាទេ។

[០៩:១៤:៥៤]

ដូច្នេះ ERN 013133 -- 01313105 ទៅដល់ 06 ហ្នឹង វាដូចជាត្រូវនឹងឯកសារលេខទី៦ទេ។ <បន្ថែមពីលើនោះទៀត នៅក្នុងតារាងនេះយើងឃើញថា មានលេខឯកសារមួយចំនួនដែលហាក់ដូចជា

មិនត្រូវគ្នានឹងលេខឯកសារភ្ជាប់មកជាមួយ> ហើយជាពិសេសហ្នឹងគឺកាលបរិច្ឆេទហ្នឹង គឺវាអត់ត្រូវគ្នាទៀត។ ឧទាហរណ៍ដូចឯកសារលេខ៧ អ៊ីចឹង ដែលមានចំណងជើងជាភាសាអង់គ្លេសថា "កិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ប៉ុល ពត ដែលចែក -- បែងចែកការងារនៅ<ថ្ងៃទី៤> ខែកុម្ភៈ ឆ្នាំ៧៦។" ហើយឯកសារភ្ជាប់និយាយពីឆ្នាំ៧៦ -- ឆ្នាំ៧៤ទេ។ <នៅក្នុងឯកសារលេខ៨ -- វាហាក់ដូចជា>អត់ត្រូវជាមួយនឹងឯកសារភ្ជាប់ ហើយឧទាហរណ៍ឯកសារទី១០ហ្នឹងចំណងជើងហ្នឹងគឺថា "សន្និសីទនៅ <នៅ៨៧០ នៅថ្ងៃទី០៥ ខែតុលា> គឺនៅឆ្នាំ៧៩។" ក៏ប៉ុន្តែ<ជាក់ស្តែង>នៅ<ពេល>ដែលយើងបើកមើលឯកសារហ្នឹង គឺខែតុលា ឆ្នាំ៧៥ទេ មិនមែនឆ្នាំ៧៩ទេ។ ដូច្នេះប្រហែលជាអង្គជំនុំជម្រះត្រូវធ្វើការកែតម្រូវទៅលើតារាងនេះ។ ហើយ ចំពោះសំណើរបស់មេធាវីការពារក្តីលោក ខៀវ សំផន នោះយើងខ្ញុំមិនមានយោបល់អ្វីទេគឺ ខាងអង្គជំនុំជម្រះសម្រេចទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន។ បើអង្គជំនុំជម្រះកំណត់ថាត្រឹមតែថ្ងៃ៣០ សីហា ក៏យើងខ្ញុំគោរពតាម បើត្រឹមថ្ងៃទី១៥ ខែកញ្ញា ក៏យើងខ្ញុំមិនយល់ទាស់អ្វីដែរ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី!

[០៩:១៦:៤១]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ខាងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនមានកត់សម្គាល់អ្វីទេ។ យើងគោរពទាំងស្រុងទៅលើការសម្រេចរបស់អង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីការពារលោក នួន ជា។

**កញ្ញា ដូរីន ជិន៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រី ភាគីទាំងអស់។ ខ្ញុំគាំទ្រការលើកឡើងរបស់មេធាវីការពារក្តី ខៀវ សំផន។ <យើងមានជំហរដូចគ្នា>។ ចំពោះយើងបញ្ហាធនធានលទ្ធភាពរបស់យើង គឺមិនអាចដាក់ទាន់ពេលវេលានោះទេ ចំពោះពេលវេលាដែលបានកំណត់។ យើងមានការងារច្រើនធ្វើណាស់។ យើងត្រូវដាក់ឯកសារនៅថ្ងៃចន្ទនិងថ្ងៃពុធ ហើយយើងក៏ត្រូវធ្វើការត្រៀមសម្រាប់ដេញដោល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សាក្សីជំនាញនៅថ្ងៃពុធផងដែរ។ <សហព្រះរាជអាជ្ញាបានដាក់ឯកសារពីរនៅសប្ដាហ៍នេះ ដែលយើងត្រូវធ្វើការឆ្លើយតបក្នុងរយៈពេលដ៏ខ្លី> ហើយយើងមានការងារច្រើនណាស់ដែលយើងត្រូវបំពេញលោកប្រធាន។ ហើយបន្ថែមទៅលើហ្នឹង ហើយការងារទាំងអស់ហ្នឹង គឺយើងមានសាក្សីដែលមកជារៀងរាល់ថ្ងៃម្នាក់ម្ដងៗ ដែលយើងត្រូវដេញដោល។ <សាក្សីម្នាក់ ក្នុងចំណោមសាក្សីដែលនឹងមកបំភ្លឺនៅសប្ដាហ៍ក្រោយ ជាសាក្សីដែលយើងខ្ញុំស្នើសុំ។ ខ្ញុំមិនដឹងថាលោកប្រធានបានជ្រាបពីរឿងនេះឬក៏យ៉ាងណានោះទេ។> ហើយយើងមានយកក្រុមយើងពាក់កណ្ដាលដែលជាក្រុមអ្នករៀបចំសេចក្ដីព្រាងដាក់ឯកសារទាំងអស់នោះ មកអង្គុយក្នុងតុលាការនេះ។ ដូច្នេះ ការងាររបស់យើងច្រើនណាស់។ ហើយសូមលោកចៅក្រមជ្រាបលើបញ្ហាទាំងអស់នេះ។

**ប្រធានអង្គជំនុំ៖**

អរគុណភាគី។ ជាបន្ត មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-232 មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[០៩:១៩:២៦]

**ប្រធានអង្គជំនុំ៖**

មុននឹងចាប់ផ្ដើមស្ដាប់សក្ខីកម្មដើមបណ្ដឹងរូបនេះ អង្គជំនុំជម្រះកត់សម្គាល់ថា សាក្សីរូបនេះត្រូវបានស្ដាប់ចម្លើយនៅក្នុងកិច្ចស៊ើបអង្កេតដែលកំពុងដំណើរការនៅក្នុងសំណុំរឿងផ្សេង។ សាក្សីចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់សាក្សីរូបនេះឋិតក្នុងក្រុម(ក) នៃក្រុមទាំងបីប្រភេទនៅក្នុងអនុស្សរណៈរបស់ខ្លួន E319/35 ហើយបានស្នើថា សាក្សីរូបនេះគួរប្រើរហស្សនាមក្នុងគោលបំណងការពារនូវភាពសម្ងាត់នៃកិច្ចដំណើរការស៊ើបអង្កេត។ អង្គជំនុំជម្រះយល់ឃើញថា វិធានការដែលមានកម្រិតបែបនេះ គឺត្រឹមត្រូវសមស្របតាមច្បាប់ក្នុងករណីបែបនេះ។ ហើយការបង្គាប់នេះ គឺត្រូវធ្វើឱ្យមានតុល្យភាពគ្នារវាងតម្រូវការនៃសាធារណភាពនៃសវនាការ ជាមួយនឹងការការពារសេរីភាពនៃការងារស៊ើបអង្កេត។ ហើយអង្គជំនុំជម្រះក៏សូមរំឭកដល់ភាគីថា ឱ្យគោរពឱ្យបានខ្ជាប់ខ្ជួននៅសេចក្ដីណែនាំនៅក្នុងឯកសារ E319/7 ក្នុងការប្រើប្រាស់ឯកសារដាក់បង្ហាញសំណុំរឿងផ្សេង។

សួស្ដីលោកដើមបណ្ដឹងរដ្ឋប្បវេណី! នៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះតាមសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺយើងបានប្រើប្រាស់តែរហស្សនាមរបស់លោក

ទេ។ ហើយលោកសាក្សីមានរហស្សនាមថា 2-TCCP-232 ហើយជាទូទៅភាគីនឹងតែងតែប្រើប្រាស់ហៅលោកក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណីប៉ុណ្ណោះ។ សូមលោកយល់ថាអង្គជំនុំជម្រះនឹងមិនអនុញ្ញាតឱ្យភាគីពាក់ព័ន្ធរួមទាំងអង្គជំនុំជម្រះខ្លួនឯងប្រើនាមត្រកូល នាមខ្លួនរបស់លោកជាសាធារណៈក្នុងនៅក្នុងសវនាការនេះទេ។

[០៩:២១:១២]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី តទៅនេះអង្គជំនុំជម្រះសូមឱ្យលោកបញ្ជាក់ពីអត្តសញ្ញាណរបស់លោកដែលមាននៅក្នុងឯកសារ E3/5733 ដែលមានលេខ ERN ជាភាសាខ្មែរ 00461845 រហូតដល់ 00411855, ERN ជាភាសាអង់គ្លេស 00850849 ដល់ 50។ មិនមានបកប្រែជាភាសាបារាំងទេនៅទំព័រនេះ។ សូមលោកដើមបណ្ដឹងពិនិត្យមើលកន្លែងដែលមានហាយឡាយពណ៌ទឹកក្រូចថាតើឈ្មោះលោក សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត មុខរបរ ឈ្មោះឪពុក ឈ្មោះម្ដាយ ឈ្មោះប្រពន្ធរបស់លោក និងចំនួនកូនរបស់លោកពិតជាត្រឹមត្រូវដែរឬទេ? លោកដើមបណ្ដឹងរដ្ឋប្បវេណីគ្រាន់តែឆ្លើយថា តើការសរសេរនេះពិតជាត្រឹមត្រូវ ឬមិនត្រឹមត្រូវបានហើយ។

[០៩:២២:៤៩]

**2-TCCP-232៖**

**ឆ៖** ត្រឹមត្រូវលោកប្រធាន។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះកោះអញ្ជើញលោកមកផ្ដល់សក្ខីកម្មថ្ងៃនេះក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះ។ ហេតុដូច្នេះ នៅចុងក្រោយបង្អស់នៃការផ្ដល់សក្ខីកម្មរបស់លោក លោកអាចមានសិទ្ធិធ្វើសេចក្ដីថ្លែងរៀបរាប់ពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម។ មានន័យថា ផលអន្តរាយដែលកើតមានចំពោះលោកក្នុងរបបកម្ពុជាប្រជាធិបតេយ្យប្រសិនបើលោកមានបំណងធ្វើដូច្នេះ។ តើលោកធ្លាប់បានផ្ដល់សក្ខីកម្ម ឬផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក ហើយប្រសិនបានធ្វើ ធ្វើប៉ុន្មានដង? ហើយធ្វើនៅកន្លែងណាខ្លះលោកចាំទេ?

[០៩:២៣:៣៨]

**ឆ៖** បាទ ខ្ញុំធ្លាប់ជួបសហចៅក្រមស៊ើបអង្កេតនៅផ្ទះ ហើយម្តងទៀតខ្ញុំធ្វើសក្ខីកម្មនៅទីនេះម្តង។

**ស៖** អរគុណលោក។ ហើយនៅមុនពេលចូលចំពោះជំនុំជម្រះនេះ តើលោកមានបានពិនិត្យមើល ឬក៏បាននៅកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុន ជាមួយអ្នកស៊ើបអង្កេតដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានអានច្រើនលើកច្រើនសារហើយលោកប្រធាន។

**ស៖** អរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ តាមសមត្ថភាពដែលលោកអាចដឹង និងចងចាំបាន តើលោកអាចបញ្ជាក់បានទេថា កំណត់ហេតុដែលស្តាប់ចម្លើយដែលលោកបានអាន ដើម្បីរំឭកការចងចាំនោះគឺពិតជាត្រឹមត្រូវសមស្របស៊ីសង្វាក់គ្នា ទៅនឹងសក្ខីកម្មដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតកាលពីពេលមុនដែរឬទេ?

**ឆ៖** បាទ បានលោកប្រធាន។

**ស៖** អរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អនុវត្តតាមបញ្ញត្តិ ៩១ស្ទួននៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីក្នុងការសួរដេញដោលដើមបណ្តឹងរូបនេះមុនភាគីដទៃទៀត។ ហើយសហមេធាវីនាំមុខ រួមជាមួយសហព្រះរាជអាជ្ញាមានរយៈពេលពីរវគ្គ។ សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

**ស៖** ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី ព្រឹកនេះ ខ្ញុំនឹងសួរសំណួរទៅកាន់លោកពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំសូមចាប់ផ្តើមដោយសំណួរទី១ ចង់សួរលោកថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកបានរៀបការដែរឬទេ?

[០៩:២៥:៤៤]

**2-TCCP-232៖**

**ឆ៖** បាទ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំមិនបានរៀបការត្រឹមត្រូវល្អទេ គឺរៀបការដោយបង្ខំ។

**ស៖** លោកអាចជម្រាបបានទេ តើការរៀបអាពាហ៍ពិពាហ៍ដោយគេបង្ខំលោកហ្នឹង រៀបចំនៅក្នុងភូមិណាឃុំណា ស្រុកណាខេត្តណាដែរ?

**ឆ៖** បាទ ការរៀបការដោយបង្ខំនេះ គឺរៀបចំនៅលើអង្គមួយ អង្គហ្នឹងគេហៅ អង្គពោន នៅក្នុងភូមិព្រៃអំពាក់ ឃុំស្រង៉ែ ស្រុកទ្រាំង ខេត្តតាកែវ។

**ស៖** លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា មុនពេលទៅដល់ឃុំហ្នឹង លោកមកពីឃុំណាដែរ?

**ឆ៖** ខ្ញុំចង់ជម្រាបជូនលោកមេធាវីថា ខ្ញុំមកដល់ឃុំហ្នឹង ខ្ញុំរស់នៅកងចល័តស្រុកស្រេចទៅហើយ។ អ៊ីចឹង ខ្ញុំមកពីឃុំរនាម ចូលមកឃុំស្រង៉ែ នៅក្នុងស្រុកទ្រាំង តាកែវហ្នឹងដដែល។

**ស៖** តើគេចាត់ទុកលោកជាប្រជាជនថ្មីមែនទេ?

**ឆ៖** បាទ ប្រជាជនថ្មីពិតប្រាកដ។

[០៩:២៧:៥៩]

**ស៖** លោកចាំទេថា លោករៀបការហ្នឹងនៅឆ្នាំណាដែរ?

**ឆ៖** បាទ ខ្ញុំរៀបការហ្នឹងនៅប្រហែលជាពាក់កណ្ដាលឆ្នាំចិតសិប -- ១៩៧៨។

**ស៖** សូមអរគុណ។ នៅពេលដែលអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតសួរលោក គឺខ្ញុំសំដៅទៅលើឯកសារ E3/4611 នៅចម្លើយទី៦ ទាំងបីភាសាលោកបានឆ្លើយថា "លោកបានរៀបការនៅចុងឆ្នាំ១៩៧៨"។ ឥឡូវនេះ លោកថា នៅពាក់កណ្ដាលឆ្នាំ៧៨។ ដូច្នេះ តើមានចំណុចអ្វីដែលធ្វើឱ្យលោកនឹកឃើញទេ លោកចាំថា នៅឆ្នាំ៧៨ហ្នឹងណា ពេលលោកការហ្នឹង តើជារដូវវស្សា ឬក៏ជារដូវប្រាំង?

**ឆ៖** បាទ សូមជម្រាបជូនថា នៅពេលដែលខ្ញុំរៀបការដោយបង្ខំនេះ ចូលរដូវវស្សាហើយ គឺមានទឹកតាមស្រែ ដក់ហូរហែហើយបាទ។ ហ្នឹងវា រៀបការហ្នឹងវា១ឆៀងចូល វាពាក់កណ្ដាលហ្នឹងវាជិតចូលទៅចុងឆ្នាំ៧៨ដែរ ប៉ុន្តែវាដូចជាក្នុង ខ្ញុំវាភ្លេចខ្លះដែរ ព្រោះ៣៧, ៣៨ឆ្នាំហើយ វាការចងចាំរបស់ខ្ញុំវាខ្សោយដែរ លោកស្រីមេធាវី។

**ស៖** អម្បាញ់មិញនេះ លោកបានឆ្លើយថាលោកជាប្រជាជនថ្មី។ ដូច្នេះ នៅមុនពេលរំដោះប្រទេសនៅខែមេសា ឆ្នាំ៧៥ នេះតើលោក<ធ្វើអ្វី>?

[០៩:៣០:៣២]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01355115



**ឆ៖** បាទ ពេលរំដោះឆ្នាំ៧៥ ថ្ងៃរំដោះភ្លាម ខ្ញុំហាក់ដូចជាសប្បាយចិត្ត អាភ្លាមៗហ្នឹង ម៉ោងប្រាំបួនហ្នឹងដូចជាសប្បាយចិត្ត។ ដល់ៗពេលម៉ោងបី ត្រូវកងទ័ពខ្មែរក្រហមហ្នឹងបណ្តេញចេញពីភ្នំពេញហ្នឹង ខ្ញុំអត់សប្បាយចិត្ត លែងសប្បាយចិត្តតែម្តង ឃើញតែសព ឃើញតែសាកសព ពាសពេញទឹកពាសពេញដី។ មានអារម្មណ៍ពិបាកចិត្តខ្លាំងណាស់។

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ ឥឡូវនេះ ខ្ញុំចង់សួរលោកថា មុនថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ តើលោកធ្វើអ្វីដែរ លោកមានមុខរបរអ្វីដែរ?

**ឆ៖** បាទ មុនឆ្នាំ១៩៧៥ ខ្ញុំសិស្សនៅវិទ្យាល័យនៅតាកែវ ហើយក្រោយមកខ្ញុំបានធ្វើជាប៉ូលិសនៅទីក្រុងភ្នំពេញបានមានស្នាក់ការនៅសាលទន្លេចតុមុខ។

[០៩:៣២:០៦]

**ស៖** កម្មាភិបាលខ្មែរក្រហមនៅភូមិ និងឃុំរបស់លោកហ្នឹងដឹងថា លោកធ្លាប់ធ្វើជាប៉ូលិសទេជាពិសេស នៅឆ្នាំ៧៨ មុនពេលរៀបការនោះ?

**ឆ៖** បាទ និយាយឲ្យច្បាស់ ព្រោះអង្គាល់មុនឆ្នាំ៧៨ មុនឆ្នាំ៧៥ និយាយអ៊ីចឹងចុះឲ្យច្បាស់។ កម្មាភិបាលភូមិ ឬក៏ពួកខ្មែរក្រហម អត់ដឹងខ្ញុំធ្វើប៉ូលិសទេ ដឹងតែខ្ញុំជាសិស្ស ហើយនិងអ្នកបួសប៉ុណ្ណឹងទេ។ ហើយបើសិនជាដឹងថាខ្ញុំធ្វើប៉ូលិស អត់បានឡើងមកធ្វើសក្ខីកម្មមកដល់ឥឡូវនេះទេ គឺបាត់ខ្លួនហើយ។

**ស៖** មុនពាក់កណ្តាលឆ្នាំ៧៨ ហ្នឹង មុនពេលដែលគេបង្ខំឲ្យលោករៀបការហ្នឹង តើលោកធ្លាប់មានគូដណ្តឹង ឬក៏ធ្លាប់ភ្ជាប់ពាក្យអីទេ?

**ឆ៖** បាទ មុននឹងខ្មែរក្រហម ឲ្យខ្ញុំរៀបការហ្នឹង ខ្ញុំមានគូដណ្តឹងដែលស្រឡាញ់គ្នាដោយស្ម័គ្រស្មោះ យល់ចិត្តគ្នាល្អណាស់ ត្រៀមតែជាប្តីប្រពន្ធដ៏ល្អបរិសុទ្ធ។ ប៉ុន្តែមកដល់ពេលហ្នឹងគឺអត់បាន។ ខ្មែរក្រហម មិនឲ្យខ្ញុំរៀបការជាមួយនាងទេ។

**ស៖** លោកអាចនិយាយរៀបរាប់ពីគូដណ្តឹងរបស់លោកបានទេ គាត់ឈ្មោះអី ហើយលោកជួបគាត់យ៉ាងម៉េច? ហើយនៅក្នុងឆ្នាំ៧៨ហ្នឹង គាត់នៅក្នុងភូមិហ្នឹងរស់នៅក្នុងភូមិហ្នឹងជាមួយលោកទេ?

[០៩:៣៤:២០]

**ឆ៖** បាទ ខ្ញុំអាចរៀបរាប់ជូនបានដោយពិស្តារ។ នារីនេះ ជានារីកូនអ្នកកំព្រាកំសត់ ប៉ុន្តែនាងមានជំនាញមុខរបរចេះរកស៊ីលក់ដូរ។ ហើយខ្ញុំ ក្នុងនាមខ្ញុំជាសិស្សនៅវិទ្យាល័យ នៅវិទ្យាល័យតាកែវ

ហ្នឹង ខ្ញុំក្រលេកឃើញនាងចេះរកស៊ីលក់ដូរ ខ្ញុំក៏ស្រឡាញ់។ ហើយខ្ញុំក៏មានសេចក្ដីស្នើដល់ឪពុកម្ដាយនាង បងប្អូននាង។ ហើយនៅក្នុងហ្នឹង ឪពុកម្ដាយនាង បងប្អូននាងក៏យល់ព្រមឲ្យខ្ញុំ ហើយខ្ញុំក៏មានការចាប់អារម្មណ៍ស្រឡាញ់គ្នាជាគូរដណ្ដឹងដោយស្មោះស្ម័គ្រអស់ពីដួងចិត្ត ស្រឡាញ់គ្នាណាស់ បាទ ដូចយើងមានចំណីអីសំខាន់សម្រាប់គូរដណ្ដឹងខ្ញុំទុកឲ្យ គឺទុកចែកគ្នាហូបដោយសប្បាយរីករាយ។ យើងសង្ឃឹមថាថ្ងៃអនាគត យើងនឹងបានជាប្ដីប្រពន្ធគ្នាដ៏ល្អ។

**ស៖** តើនាងរស់នៅជាមួយ -- នៅភូមិ ឬក៏ឃុំជាមួយលោកទេនៅពាក់កណ្ដាលឆ្នាំ៧៨ ខណៈពេលដែលគេបង្ខំឲ្យលោករៀបការនោះ? គាត់រស់នៅកន្លែងតែមួយជាមួយលោកមែនទេ?

**ឆ៖** បាទ លោកស្រីមេធាវី កាលនោះខ្ញុំនៅកងចល័តស្រុក១០៧ នាងក៏នៅកងចល័តស្រុក១០៧ហ្នឹងដែរ ប៉ុន្តែនាងនៅកងនារីផ្សេង ខ្ញុំនៅកងយុវជន ប៉ុន្តែខ្ញុំមិនអាចទំនាក់ទំនងគ្នាបានទេ ព្រោះនៅពេលនោះ បើយើងមានទំនាក់ទំនងគ្នាពីរឿងស្នេហា ឬក៏និយាយគ្នារបៀបថាស្រឡាញ់គ្នាហ្នឹង ក៏មេកងចល័តហ្នឹងមិនទុកដែរ យកទៅកម្ទេចចោលហើយ នឹងកម្ទេចចោលគឺសម្លាប់ចោលតែម្ដងគ្មានទុកទេ។ អ៊ីចឹងយើងអត់មានបានជួបគ្នាទេ។ គ្រាន់តែដឹងថានាងនៅកងនារី ខ្ញុំនៅកងយុវជន។

[០៩:៣៧:១៦]

**ស៖** លោកអាចជម្រាបជូនតុលាការបានទេថា ពេលហ្នឹងម៉េចបានលោកដឹងថា លោកត្រូវរៀបការ?

**ឆ៖** ខ្ញុំសូមជម្រាបជូនលោកប្រធាន ខ្ញុំដឹងរៀបការហ្នឹង ដោយកាលនោះកងទ័ពវៀតណាមបានវាយបុករហូតមកដល់ខេត្តតាកែវហ្នឹង បើយើងគិតជាចម្ងាយប្រហែលជា៤០គីឡូហើយ អ៊ីចឹងខ្ញុំ គេចាត់ទុកខ្ញុំថាជាអ្នកមានប្រវត្តិរូបល្អ ហើយធ្វើការខ្ញុំមិនដែលតវ៉ាទេ ខ្ញុំរែកដីបង្គីធំៗណាស់។ អ៊ីចឹងគេឃើញខ្ញុំស្គម មានតែឆ្អឹង ប្រធានកងនោះថាមិត្តឯងចាស់ហើយ មិត្តឯងអង្គការឲ្យរកគ្នីរកគ្នារកគ្រួសារទៅ។ អ៊ីចឹងបានគេនិយាយតែប៉ុណ្ណឹង ខ្ញុំក៏នៅស្ងៀមទៅ ខ្ញុំមិនមានវាចាអីតបទៅជាមួយប្រធានកងទេ ព្រោះខ្ញុំមិនដែលមើលមុខប្រធានកងចំទេ ខ្លាចៗគេរហូត។

**ស៖** នៅពេលណាដែលលោកដឹងពីអត្តសញ្ញាណរបស់អ្នកដែលនឹងត្រូវក្លាយជាប្រពន្ធរបស់លោកនោះ?

[០៩:៣៩:៣០]

**ឆ៖** ខ្ញុំអត់បានដឹងទេលោកស្រីមេធាវី អត់ដឹងសោះ។ គឺដឹង បើសិនគេដឹងៗថាពួកខាងកងនារី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បានដឹង ចំពោះការកងយុវជន គឺប្រុសៗហ្នឹងអត់មានដឹងទេ អត់មានដឹងទាល់តែសោះ។ ហើយខ្ញុំគ្រាន់តែជម្រាបជូនព័ត៌មានមួយ ថ្ងៃមួយគេយកកងនារីដាក់មួយកង១០នាក់ យុវជន១០នាក់ តម្រៀបក្បែរៗគ្នាជីកប្រឡាយ។ មេកងថា បើបានយុវជននិយាយជាមួយនារី គ្រាន់តែញញឹមដាក់ ក៏យកទៅរៀនសូត្រកម្មេចចោលដែរ។ អ៊ីចឹងយើងខ្ញុំរស់នៅកងចល័តហ្នឹង វេទនាណាស់ មិនបានចេញស្តីអីទេ ដឹងតែឱនធ្វើការងារហ្នឹងទៅ ឱនធ្វើការងារ ចង់បងប្អូន ឬក៏ជួបមិត្តនារីហ្នឹងជាបងជាប្អូន ក៏អត់បាននិយាយរកដែរ មិនបាននិយាយរកទេ កាលណាបាននិយាយរក គឺមានកងឈ្លបកងអីហ្នឹង មកចាប់យើងភ្លាមទៅចាប់ភ្លាមហើយបាត់ខ្លួនហើយ។ បាទ មានប៉ុណ្ណឹង។

**ស៖** តើលោកធ្លាប់ស្នើថាចង់រៀងការជាមួយនឹងគូដណ្តឹងដែលធ្វើការនៅកងចល័តដូចលោកហ្នឹងទេ?

**ឆ៖** ខ្ញុំមិនដែលស្នើទេ លោកមេធាវី ខ្ញុំមិនដែលស្នើសោះ ខ្ញុំខ្លាចណាស់ ខ្ញុំដឹងតែធ្វើការងារជូនបដិវត្តន៍ ខ្ញុំមិនបានទេ គេឲ្យហូបអី ខ្ញុំហូបហ្នឹង គេឲ្យធ្វើអី ខ្ញុំធ្វើហ្នឹង ខ្ញុំអត់បានទេ ខ្ញុំមិនដែលស្នើទេ។ ព្រោះខ្ញុំប្រជាជនថ្មី អត់មានសិទ្ធិ គឺគ្មានសិទ្ធិនិយាយស្តីអីច្រើនជាមួយគេ មានតែអ្នកមូលដ្ឋានទេ អាចមានសិទ្ធិនិយាយ ឬក៏ស្នើអីបាន។ ចំពោះខ្ញុំជាមនុស្សថ្មី របស់ខ្មែរក្រហមកាន់កាប់ ខ្ញុំគ្មានសិទ្ធិអីនិយាយទេ។ លោកមេធាវី។

**ស៖** មុននេះ លោកឆ្លើយថា លោកមិនដឹងអត្តសញ្ញាណប្រពន្ធរបស់លោកទេ មុនពេលរៀប-ការ។ ដូច្នេះខ្ញុំចង់ដឹងថា នៅពេលណាដែលលោកជួបប្រពន្ធរបស់លោក? ហើយនៅពេលណាដែលគេពន្យល់ប្រាប់លោកថា ស្ត្រីម្នាក់ហ្នឹងនឹងត្រូវមករៀបការជាប្រពន្ធរបស់លោកនោះ?

[០៩:៤២:៣០]

**ឆ៖** ខ្ញុំសូមជម្រាបជូនថា ខ្ញុំមិនដែលឃើញនាងហ្នឹងទេ ពេលដែលអើ ពេលដែលត្រូវមកប្តេជ្ញា គេមករៀបគូខ្ញុំចុងក្រោយទី៥០ហ្នឹង ខ្ញុំគូទី៤២ហ្នឹង មិនបានឃើញមុខនាងហ្នឹងផង នាងហ្នឹងមកឈរក្បែរខ្ញុំ ក៏ខ្ញុំមិនបាន គឺថាយើងឈរមើលទៅមុខ មើលតែមុខមេកង មិនដឹងនាងរបៀបម៉េចៗផង ខ្ញុំមិនស្គាល់។ តាំងពីអត្តសញ្ញាណរូបរាងរបៀបម៉េច ក៏ខ្ញុំអត់ដឹងដែរ ខ្ញុំអត់បានមើលទេ អត់បានមើលទេ មិនដឹងមើលម៉េច ព្រោះខ្ញុំខ្លាចប្រធានកងខ្លាំងណាស់។

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ នៅពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេតសួរលោក គឺនៅចម្លើយទី៦ដដែល ឯកសារ E3/4611 លោកបានឆ្លើយដូចតទៅ ខ្ញុំសូមដក

ស្រង់ លោកថាលោកបានប្រាប់ រី <ប្រធានកងរបស់លោក>ថាលោកមានគូដណ្ដឹង។ លោកបានថាដូចតទៅ៖ "រី បានសួរខ្ញុំថា តើគូដណ្ដឹងខ្ញុំមានសាច់ញាតិ ឬបងប្អូនត្រូវបានកម្ទេចដោយអង្គការដែរឬទេ។ ខ្ញុំបានប្រាប់ រី ថាបងប្រុសរបស់គូដណ្ដឹងរបស់ខ្ញុំជាទាហាន ហើយត្រូវបានអង្គការកម្ទេច។ រី និយាយថា ខ្ញុំមិនអាចរៀបការជាមួយនាងបានទេ។ រី បានប្រាប់ថែ្លមទៀតថា បើសិនខ្ញុំជាកូនអង្គការ នោះអង្គការនឹងរកនារីម្នាក់រៀបការឲ្យខ្ញុំ។" ដូច្នេះនៅថ្ងៃនេះ តើលោកចាំទេថា លោកបានប្រាប់ រី ដោយត្រង់ថាលោកមានគូដណ្ដឹង? លោកអាចពន្យល់លម្អិតបានទេ <តើមានអ្វីកើតឡើងនៅពេលក្រោយមកទៀត>?

[០៩:៤៤:៤៤]

**ឆ៖** បាទលោកស្រីមេធាវី ខ្ញុំអាចជម្រាបជូនបាន។ ពេលដែលប្រធានកង រី ហៅខ្ញុំៗកំពុងតែនឹងពង្រាបដី រែកដីពីដីខ្ពស់ទៅដាក់ដីទាប។ ឃើញនីរសារគាត់មកហៅខ្ញុំថា "មិត្តតា ប្រធានកងហៅ!" ខ្ញុំក៏ដាក់ដងរែកចុះ បន្ដឹចុះរួចរត់ទៅ លត់ជង្គង់មុខគាត់ ហើយមេកងបានសួរខ្ញុំថា "សមមិត្តឯងចង់រៀបការដែរឬទេ? ខ្ញុំបានឆ្លើយថា៖ ស្រេចតែលើបងទេ"។ រួចហើយមេកងហ្នឹងសួរមេកង រី ហ្នឹង មេកងរីសួរខ្ញុំទៀតថា "មិត្តឯងមានគូដណ្ដឹងទេ? ខ្ញុំឆ្លើយថា៖ បាទ មាន។ ហើយគូដណ្ដឹងនៅឯណា? ខ្ញុំប្រាប់ថានៅភូមិជាមួយគ្នា ហើយគូដណ្ដឹងហ្នឹងមានបងប្អូនអង្គការកម្ទេចឬទេ? ខ្ញុំឆ្លើយត្រង់ៗថា បាទ មានៗបងប្រុសគាត់មួយត្រូវអង្គការកម្ទេច"។ អ៊ីចឹងប្រធានកងរី ហ្នឹង បានសួរខ្ញុំទៀតថា "បើមានអង្គការកម្ទេចអ៊ីចឹងមិត្តឯងមិនអាចរៀបការជាមួយនារីហ្នឹងបានទេ ព្រោះថ្ងៃក្រោយ ទៅមិត្តឯងនឹងស្លាប់តាមបងប្អូនរបស់នារីហ្នឹងហើយ ព្រោះនារីហ្នឹងស្ថិតនៅក្នុងការតាមដានរបស់អង្គការ។ អ៊ីចឹងបើកាលណាសម្លាប់នារីហ្នឹង ក៏សម្លាប់មិត្តឯងដែរ។ អ៊ីចឹងមិត្តឯងត្រូវដូរចិត្ត ធ្វើម៉េច ឥឡូវខ្ញុំឲ្យមិត្តឯងធ្វើជាកូនអង្គការ។ មិត្តឯងយល់យ៉ាងម៉េច ពិចារណាមើល ចង់ងាប់ ហើយចង់រស់? បើយកនារីហ្នឹងមានតែងាប់ហើយ គឺការកម្ទេចដកស្មៅទាំងឫស។" មេកងហ្នឹងនិយាយថាអ៊ីចឹង។

[០៩:៤៧:១៦]

ហើយឲ្យខ្ញុំឆ្លើយប្រញាប់ៗ ថាត្រូវឆ្លើយឲ្យញាប់ៗមក ប្រញាប់ៗមក មាននៅគេច្រើនណាស់។ ខ្ញុំស្រេចតែលើបងទេ បងជាម៉ែជាឪខ្ញុំហើយ អើជាកូនអង្គការ? គាត់សួរថា "ទី១ ធ្វើកូនអង្គការទេ?" ដោយខ្ញុំខ្លាចស្លាប់ទាំងនារីជាគូដណ្ដឹង ដោយខ្ញុំខ្លាចស្លាប់នឹងខ្លួនខ្ញុំ ដោយនឹកឃើញដោយខ្លាចស្លាប់ដល់បងប្អូនច្រើនទៀត ខ្ញុំសុខចិត្តឆ្លើយថា "ជាកូនអង្គការ"។ រួចប្រធានកងសួរលើកទី២ "កូនអង្គការ? បាទ កូនអង្គការ"។ សួរគ្រប់បីដងៗ "កូនអង្គការ? ខ្ញុំឆ្លើយថា៖ បាទ កូនអង្គការ"។ ដើម្បីរួចរស់ជីវិតត្រូវតែ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឆ្លើយ រួចគាត់កត់កំណត់ហេតុក្នុងសៀវភៅហ្នឹង ហើយមេកងរី ហ្នឹងកត់កំណត់ហេតុលេខ១ លេខ២ លេខ៣អ៊ីចឹងទៅ ថាខ្ញុំហ្នឹងសុខចិត្តហើយ បើខ្ញុំមិនសុខចិត្តធ្វើតាមទេ ឬខ្ញុំប្រឆាំងថាមិនមែនកូនអង្គការ មិនធ្វើតាមការណែនាំរបស់មេកង ខ្ញុំមិនដឹងត្រូវ ប្រហែលជាទៅមន្ទីរខក្រិដ្ឋកម្មណាមួយបាត់ហើយ។ បើខ្ញុំឆ្លើយអ៊ីចឹងទៅ គឺខ្ញុំបានរួចខ្លួន។ មានតែប៉ុណ្ណឹងលោកមេធាវី។

**ស៖** សូមអរគុណ ដែលបានឆ្លើយបញ្ជាក់នេះ។ ឥឡូវមុននឹងត្រឡប់ចូលមកនិយាយអំពីពិធីហ្នឹង នៅពេលហ្នឹងលោកបានស្គាល់ប្រពន្ធលោកហ្នឹង។ ឥឡូវខ្ញុំចង់ដឹងថា តើនៅពេលណាមួយនោះមានកិច្ចប្រជុំមុនពេលរៀបការហ្នឹងដែរឬទេ? ពេលកិច្ចប្រជុំហ្នឹងគេប្រាប់លោកថា នែ! បន្តិចទៀតនេះលោកនឹងរៀបការហើយ មានទេកិច្ចប្រជុំបែបហ្នឹង?

[០៩:៤៩:១៣]

**ឆ៖** បាទ មិនមានកិច្ចប្រជុំអីធំដុំទេ គ្រាន់តែហៅគ្នាខ្ញុំប្រុសៗហ្នឹង ប្រហែលយុវជនហ្នឹងប្រហែលជាបីបួននាក់។ ថា "មិត្តឯងបីបួននាក់នេះ ខ្ញុំនឹងឲ្យមិត្តឯងមានគូស្រករហើយ ព្រោះឃើញមិត្តឯងហ្នឹងចាស់ៗហើយ មិត្តឯងធ្វើការងារល្អ"។ គ្រាន់តែមានប៉ុណ្ណឹងទេ គេមិនដែលប្រជុំថាម៉េចទេ ព្រោះគេរវល់ឲ្យយើងពង្រាបដី លើកភ្លឺស្រែ ធ្វើការជីកប្រឡាយខ្លាំងណាស់ អ៊ីចឹងគេអត់មាននៅប្រជុំទេ គេគ្រាន់តែប្រាប់ប៉ុណ្ណឹងហើយថា "មិត្តឯងចាំ! តិចទៀតយើងឲ្យមិត្តឯងមានគូស្រករហើយ"។ បាទ មានតែប៉ុណ្ណឹង គេមិនមានប្រជុំអីទេ។

**ស៖** ខ្ញុំសូមអរគុណ។ មូលហេតុដែលខ្ញុំសួរសំណួរនេះទៅលោកនេះ ពីព្រោះថានៅក្នុងព័ត៌មានបន្ថែមរបស់លោកនោះ គឺឯកសារ E3/4612, ERN ជាភាសាបារាំងគឺ 00938428, ជាភាសាខ្មែរ គឺ 00580746 ទៅដល់ 47, ជាភាសាអង់គ្លេសគឺ 00861858។ មានសរសេរដូចតទៅនេះនៅក្នុងទម្រង់ព័ត៌មានបន្ថែមរបស់លោក ខ្ញុំចង់បញ្ជាក់ថា តើវាត្រឹមត្រូវដែរឬអត់។ មានសរសេរនៅក្នុងឯកសារនេះ៖ "ថ្ងៃមួយប្រធានក្រុម ពុត <និង រី> បានកោះហៅខ្ញុំ<ទៅប្រជុំ>ជាមួយអ្នកផ្សេងទៀត ប្រុស៥០ នារី៥០។ ប្រធានឈ្មោះ ពុត ហ្នឹងគាត់និយាយថា ពួកយើងទាំងអស់ហ្នឹងជាកូនរបស់អង្គការ ហើយឥឡូវយើងគ្រប់អាយុនឹងរៀបការហើយៗ។ អង្គការនឹងរៀបការពួកយើង អ៊ីចឹងត្រូវគោរពតាមអង្គការ។ បើយើងជំទាស់អង្គការ គឺគេនឹងយកទៅកម្ទេចចោលដូចពួកនៅតំបន់៣៣អ៊ីចឹង។" ហើយនៅក្នុងឯកសារដដែលនេះសរសេរថា <កិច្ច>ប្រជុំនុ៎ង<ធ្វើឡើង>៣ខែមុន<រៀបការ> "យើងមិនដឹងថា អ្នកណានឹងត្រូវរៀបការជាមួយអ្នកណាទេ"។ អ៊ីចឹងសំណួរខ្ញុំដូចតទៅនេះ លោកបាននិយាយពីកិច្ចប្រជុំមួយជាមួយ

នឹងមនុស្សបីបួននាក់ផ្សេងទៀត។ នៅក្នុងឯកសារហ្នឹងគេនិយាយពីមនុស្សប្រុស៥០ មនុស្សស្រី៥០។ មានឧទាហរណ៍មួយទៀតដែល ពុត <និង វី> ហ្នឹងគាត់ប្រាប់<>ទាក់ទងនឹងតំបន់៣៣។ ហើយលោកឆ្លើយថា កិច្ចប្រជុំហ្នឹងទំនងជាបានប្រព្រឹត្តទៅ៣ខែមុនពិធីរៀបការហ្នឹង។ តើលោកចាំទេ ព័ត៌មានទាំងអស់នេះ វាស៊ីគ្នានឹងការចងចាំរបស់លោកដែរឬទេ? តើលោកអាចជម្រាបជូនតុលាការអ្វីខ្លះទាក់ទងនឹងចំណុចនេះ?

[០៩:៥២:១៩]

**ឆ៖** បាទ ខ្ញុំសូមជម្រាបជូនថា រយៈពេល៣ខែហ្នឹង អាហ្នឹងលោក វី ហ្នឹងបានប្រាប់យូរហើយ។ ក៏ប៉ុន្តែដល់ពេលនេះ ខ្ញុំសុំជម្រាបជូនអត្តសញ្ញាណរបស់លោក ពុត។ ពុត ហ្នឹងបើគិតទៅនៅក្នុងស្រុកខ្ញុំហ្នឹង សម័យកងចល័តហ្នឹង គាត់ដូចជាចៅហ្វាយស្រុកមួយអ៊ីចឹង ផ្នែកខាងយុវជននារីលើគាត់ទទួលខុសត្រូវ។ ហើយគាត់បាននិយាយថា អ្នកទាំង៥០គូហ្នឹង ប្រុស៥០ ស្រី៥០ ជាកូនអង្គការហើយ។ អ៊ីចឹងអ្នកទាំងអស់គ្នាហ្នឹងត្រូវតែគោរពអង្គការ។ អាហ្នឹងខ្ញុំនិយាយនេះ ខ្ញុំនិយាយនៅនឹងពេលប្ដេជ្ញាទេ ព្រោះដល់ពេលកន្លែងប្ដេជ្ញាហើយ។ ពុត ហ្នឹងនិយាយថាអ៊ីចឹង កូនអង្គការអត់មានអ្នកណាតវ៉ាអីទេ។ ហើយគាត់និយាយថា ដូចតំបន់៣៣ហ្នឹង។ ៣៣ហ្នឹង គឺខេត្តកំពង់ស្ពឺ។ គេរៀបមង្គលការហ្នឹងមានយុវជននារីហ្នឹង នៅប្រាសាទភ្នំដា ភ្នំបុរីហ្នឹង ស្រុកអង្គបុរី ខេត្តតាកែវយើងដែរហ្នឹង។ នារីហ្នឹងបានប្ដីអាក្រក់ ដល់បុរសស្អាតហ្នឹងបាននារីអាក្រក់។ គេនាំគ្នាហ្នឹងទៅបន់អ្នកតាហ្នឹង។ នារីស្អាត់ហ្នឹង គេបន់អ្នកតា ថាឲ្យកាច់ប្ដីងាប់ទៅ។ ហើយបុរសរូបស្អាតហ្នឹង គេបន់អ្នកតាហ្នឹងឲ្យកាច់ប្រពន្ធងាប់ទៅ។ ដល់មេកងខ្មែរក្រហមនៅតំបន់៣៣ហ្នឹងគេដឹង ប្រធានកង ពុត ថាបើធ្វើដូចតំបន់៣៣ហ្នឹង គឺកម្ទេចចោលទាំងអស់។ អ៊ីចឹងនៅនារី-បុរសនៅ៣៣ហ្នឹង គេបន់អ្នកតាភ្នំបុរីហ្នឹងឲ្យកាច់។ អាហ្នឹងខ្ញុំនិយាយតាមពាក្យរបស់ប្រធានកង ពុត គឺសម្លាប់ចោលទាំងពីរតែម្ដង។ អាស្អាតក៏សម្លាប់ មិនស្អាត់ក៏សម្លាប់ សម្លាប់ចោលច្រើន។ ខ្ញុំបានដឹងខ្លះដែរ នៅខាងកើតភ្នំបុរីហ្នឹង មានឆ្អឹងគរច្រើនដែរ ព្រោះខ្ញុំកាលកងចល័ត ខ្ញុំទៅដើរក្នុងព្រៃហ្នឹង រកឧសរកអីទៅឃើញមានឆ្អឹងនៅគរ ដូចជាដំបូកដែរ ប៉ុនមិនដឹងឆ្អឹកស្អីទេ ឃើញច្រើនណាស់នៅខាងកើតភ្នំ។ ប្រហែលជាឆ្អឹងរបស់នារីយុវជនហ្នឹងក៏មិនដឹង ហើយក៏ឆ្អឹងរបៀបម៉េចទេ។ ខ្ញុំអត់បានសិក្សាច្បាស់លាស់ទេ។ សុំចប់ប៉ុណ្ណឹង។

[០៩:៥៥:១៥]

**ស៖** សូមអរគុណ។ ឥឡូវនេះ ទៅនិយាយពីថ្ងៃដែលរៀបការហ្នឹងតែម្ដង។ តើលោកអាច

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជម្រាបជូនតុលាការបានដែរឬទេ ថាពិធីរៀបការហ្នឹងប្រព្រឹត្តទៅយ៉ាងដូចម្ដេចដែរ? គឺនៅម៉ោងប៉ុន្មាន? នៅកន្លែង<ណា>? ហើយអ្នកណាជាអធិបតីនៃពិធីរៀបការហ្នឹង? តើគូទាំងអស់ហ្នឹងឈរនៅកន្លែង ណា ហើយពួកគាត់ធ្វើអីខ្លះ? អ៊ីចឹងលោកអាចជម្រាបជូនតុលាការអំពីពិធីហ្នឹងបានទេ?

**ឆះ** បាទ ខ្ញុំអាចជម្រាបជូនលោកប្រធានបាន។ ថ្ងៃមួយ យប់មួយនោះ គឺ មេកងរី ហ្នឹងបាន ប្រាប់ឲ្យនីរសាររបស់គាត់ហ្នឹងដើរប្រាប់យុវជនឲ្យអស់ ប៉ុន្តែៗការរៀបការហ្នឹងនៅលើទួលហ្នឹងគេហៅ អង្គពោន។ អង្គពោន ហ្នឹងនៅក្នុងភូមិព្រៃអំពាក់ ឃុំស្រង៉ែ ស្រុកទ្រាំង ខេត្តតាកែវហ្នឹង។ ប៉ុន្តែគេធ្វើរោង មួយ ធ្វើរោងមួយវែង ហើយរោងមួយទៀតតូចដែរ ខ្លីសម្រាប់ ប្រធានកង ពុត ហ្នឹងហើយនិងប្រធាន កងនារី។ ប្រធានកងនារីហ្នឹងធំជាងគេមិនដឹងឈ្មោះអីដែរស្មើលោក ពុត ហ្នឹងដែរ ខ្ញុំមិនដឹងទេ។ សម មិត្តពុត ហ្នឹងដែរប៉ុនអត់ស្គាល់។ អ៊ីចឹងគេហៅយុវជនហ្នឹង ៥០នាក់មកមុន ហៅមកមុនហើយ គេឲ្យ រៀបលេខ ឈរតាមលេខរៀង លេខ១ លេខ២ រហូតដល់ ៥០នាក់។ ហើយមកគេអប់រំយុវជនហ្នឹង ថា ថ្ងៃនេះមិត្តទាំងអស់គ្នាត្រូវអង្គការឲ្យមានគ្រួសារហើយ។ គេអប់រំណែនាំសព្វបែបយ៉ាង តាំងពីឲ្យដើរ តាមអង្គការកុំខុសឆ្គងជាមួយអង្គការ ត្រូវតែគោរពអង្គការ អង្គការជាឪពុកម្ដាយរបស់យើង មានឪពុក ម្ដាយណាធំជាងអង្គការទេ គឺមានតែអង្គការ។ រួចហើយគេបំបែកចេញ គេឲ្យទៅម្ដង១០នាក់ ឲ្យយុវជន ១០នាក់អ៊ីចឹងមកឈរមុខអ៊ីចឹងទៅមុខ មេកងពុត មេកងរី ហើយមេកងច្រើនទៀត។ ហើយមេកងនារី ហ្នឹងនៅឈរជុំវិញរោងហ្នឹងទាំងអស់។

[០៩:៥៧:៥៦]

ដល់ពេលយុវជន១០នាក់ហ្នឹងមកឈរហើយ ទើបប្រធានកង ពុត ហ្នឹងប្រាប់ថា នារីប៉ែត។ នារី ប៉ែត ហ្នឹងក៏ជានារី ជាមេកងមួយដែរ ទៅនាំនារី១០នាក់មក។ អ៊ីចឹងនារី១០នាក់ហ្នឹងដើរចូលតាមជួរ មក ឈរតាមលេខរៀងហ្នឹងទៅ។ ដល់ឈរអ៊ីចឹងហើយ បានហើយក៏មេកងហ្នឹងផ្សេងទៀតឡើងមាន យោបល់អប់រំគ្នាឲ្យស្រឡាញ់គ្នាអ៊ីចឹង។ ដល់ពេលអប់រំចប់ បានឲ្យឡើងម្នាក់ ឲ្យប្រុសឈរមុខ ឈរនៅ មុខទី១ហ្នឹងឡើងប្ដេជ្ញា។ ហើយម្នាក់ៗឡើងប្ដេជ្ញាគោរពអង្គការ ស្រឡាញ់អង្គការ ខ្ញុំស្រឡាញ់គូដណ្ដឹងខ្ញុំ ស្រឡាញ់អ៊ីចឹងហូរហែអ៊ីចឹងមក។ រហូតដល់ចប់ បាននារីប្ដេជ្ញាម្ដងថា ស្រឡាញ់គ្នាអ៊ីចឹងអស់មួយជីវិត អីហូរហែអ៊ីចឹងទៅ។ រហូតហើយអ៊ីចឹងទី១ហ្នឹងឡើងមកក្រោយ លេខ២ ហ្នឹងគូទី២ ឡើងប្ដេជ្ញាតៗគ្នា អ៊ីចឹងរហូតដល់ចប់ ទៅ១០គូហ្នឹងចេញទៅ ចូលមក១០គូទៀត ធ្វើតាមអ្នកហ្នឹងដដែល។ ប៉ុន្តែខ្ញុំនៅគូទី ១០នាក់ដែរ មិនមែនខ្ទង់៥០។ ៤១, ៤២ រហូតដល់ ៥០។ ខ្ញុំនៅគូទី៤២។ ដល់ខ្ញុំហ្នឹងចូលមកដល់គូហ្នឹង

ដែរ ខ្ញុំឈរដូចគេដូចឯងអ៊ីចឹង បាននារីប៉ែត ហ្នឹងនាំនារីហូរហែដូចគ្នា។ មាននៅក្នុងកងហ្នឹងមានអ្នកខ្លះគេបានគូដណ្តឹងគេពិតប្រាកដដែលគេដណ្តឹងបាន អាហ្នឹងរបស់គេមានប្រវត្តិថាប្រវត្តិរូបគេល្អអ៊ីចឹងចុះ។ ប៉ុន្តែខ្ញុំអត់បានដឹងទេ ខ្ញុំគូដណ្តឹងខ្ញុំក៏មិនហ៊ានមើលមុខគេ មិនហ៊ានមើលអី ដឹងតែមើលមុខប្រធានកងតែប៉ុណ្ណឹងទេ។ ហើយមកដល់ពេលខ្ញុំប្តេជ្ញា ខ្ញុំប្តេជ្ញាខ្លី ខ្ញុំមិនដឹងនិយាយថាម៉េច ខ្ញុំថា "សូមគោរពអង្គការជាឪពុកម្តាយដ៏ល្អ អ៊ីចឹងហើយអង្គការឲ្យខ្ញុំធ្វើអី ខ្ញុំគោរពតាមអង្គការជារៀងរហូត" ខ្ញុំប្តេជ្ញាខ្លីតែប៉ុណ្ណឹង។ ហើយមេកង ពុត គេថា "នែ! ប្តេជ្ញាតាមសមមិត្តហ្នឹង ខ្លីៗអ៊ីចឹងស្រួល កុំនៅវែងពេក ឲ្យតែដើរតាមអង្គការវាមិនងាប់ទេ"។ អ៊ីចឹងបាទថាមានតែប៉ុណ្ណឹង។ លោកមេធាវី លោកប្រធាន ជម្រាបជូនបានប៉ុណ្ណឹង។

[១០:០០:៤៧]

**ស៖** សូមអរគុណ។ តើនៅពេលណាដែរ ដែលលោកដឹងអំពីឈ្មោះអត្តសញ្ញាណ<និងឈ្មោះ> របស់បុគ្គល ដែលនឹងក្លាយជាប្រពន្ធរបស់លោកនៅថ្ងៃនោះហ្នឹង? តើនៅពេលណាដែរ ដែលលោកបានដឹងអំពីអត្តសញ្ញាណរបស់គាត់?

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំសូមជម្រាបជូន ពេលខ្ញុំរៀបការរួច មេកងគេឲ្យទៅតាមកងយុវជនវិញ នារីទៅតាមយុវនារីវិញ។ ដល់ពេលស្អែកឡើង ខ្ញុំនិងមិត្តទាំងអស់គ្នាហ្នឹង ចេញទៅធ្វើការទៅលើកភ្លឺ ហើយនិងខ្លះលើកជីកប្រឡាយអ៊ីចឹងទៅ ខ្លះពង្រាបដីអ៊ីចឹងទៅពេញមួយថ្ងៃ។ ដល់ពេលយប់ហូបបាយហូបអីហើយហ្នឹង ពេលយប់អាហ្នឹងដូចថា យើងមើលគ្នាលែងស្គាល់ហើយ ហើយមានគេធ្វើថែបហ្នឹង គេកាប់ដីដាក់ធ្វើដូចជារងស្ពៃអ៊ីចឹង ហើយដាក់ថែប ចងដាក់ពីលើអ៊ីចឹង។ ប្រធានកង រី ហ្នឹងដើរពង្រាយថា មិត្តឯងធ្វើតាមថែបហ្នឹងទៅ។ ខ្ញុំក៏ទៅឈរតាមមេកងគេបញ្ជាអ៊ីចឹង ក្រោយមកបានជានារីប៉ែត ហ្នឹងនាំប្រពន្ធដែលយើងរៀបការមិនស្គាល់មុខហ្នឹង យកមកឲ្យយើងម្នាក់មួយៗគ្រប់គ្នាអ៊ីចឹងទៅចែកតាមថែប អ៊ីចឹងទៅ។ ចែកហើយគេបញ្ជាថាឲ្យរៀបចំកន្លែងដេកទៅ។ ចូលដេកចូលអីក្នុងថែបទៅអត់មានឈរនៅខាងក្រៅទេ។ ហើយខ្ញុំបាទហ្នឹងក៏ ថែបហ្នឹងវាចង្អៀតដែរ ប៉ុន្តែចេះតែចូលដេកតាមគេទៅ បើយើងមិនចូលដេកធ្វើតាមមេកងហ្នឹងទេ អាហ្នឹងវាមានវិធានការទៀតហើយ។

[១០:០២:៥០]

អ៊ីចឹង ខ្ញុំចេះតែចូលដេកទៅជាមួយគ្នាអ៊ីចឹងទៅ ដូចជាបងជាប្អូនទៅ មិនមែនជា មិនទាន់ប្រព្រឹត្តអ្វីខុសឆ្គងទេ គឺយើងគ្រាន់តែដេកជាមួយគ្នាជាបងជាប្អូន ព្រោះសម័យនោះ មិនមានសាច់ឈាមដុំកំភួន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដូចសម័យឥឡូវនេះទេ។ ស្គមស្គាំង ឃើញតែឆ្អឹង ឃើញតែសរសៃ ភ្នែកសស្គុស នៅប្រឹងទៅដេករួមដំណេកក៏គ្មាន ពិបាក ដែរ។ អ៊ីចឹង ខ្ញុំដេកជាមួយគ្នាជាបងជាប្អូន ហើយស្គាល់គ្នា ពេលហ្នឹងស្គាល់មិនច្បាស់ទៀតនោះ ពេលយប់ ពេលយប់ងងឹតទៅ ប៉ុន្តែយើងចេះតែដេកទៅ ដល់ភ្លឺឡើងបានយើងស្គាល់គ្នា។ ស្គាល់គ្នាហើយចេញទៅធ្វើការរៀង១ខ្លួនទៀត អត់មាននៅក្នុងរោងហ្នឹងទេ ក៏ប៉ុន្តែមេកងប្រាប់ខ្ញុំថា សមមិត្តឯងនៅរៀបចំថែបហ្នឹងធ្វើអីរៀបចំបង្ហាប់ដី ធ្វើថែបហ្នឹងឲ្យខ្ពស់ បិទបាំងឲ្យជិតត្រឹមត្រូវ។ ហើយខ្ញុំនៅធ្វើថែបហ្នឹងមួយថ្ងៃ។ ចំណែកនារីគេទៅធ្វើការដកស្ទូងបាត់ទៅ។ មានតែប៉ុណ្ណឹងសូមជម្រាបជូន។

[១០:០៥:១២]

**ស៖** សូមអរគុណដែលបានឆ្លើយបញ្ជាក់។ ឥឡូវ ខ្ញុំសូមត្រឡប់មកនិយាយពីពេលក្រោយបន្តិចដើម្បីសួរឲ្យលោកមានប្រតិកម្មទាក់ទងនឹងពិធីរៀបការនេះ។ តើពិធីការហ្នឹង ពិធីរៀបការហ្នឹងវាដូចស្រដៀងគ្នានឹងពិធីរៀបការផ្សេងទៀត ដែលលោកបានចូលរួមពេលមុន ហើយនិងពេលក្រោយរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? អ៊ីចឹងលោកអាចជម្រាបជូនតុលាការបានដែរឬទេ ពេលដែលលោករៀបការនៅឆ្នាំ១៩៧៨ ពាក់កណ្តាល១៩៧៨ហ្នឹង ធៀបទៅនឹងពិធីការមុនរបបខ្មែរក្រហម ហើយនិងក្រោយរបបខ្មែរក្រហមហ្នឹង វាខុសគ្នាយ៉ាងម៉េចដែរ?

**ឆ៖** បាទ សូមជម្រាបជូន។ ព្រោះនៅក្នុងសម័យសម្តេច សីហនុ និងសម័យសម្តេច លន់ នល់ សម័យលោករដ្ឋមន្ត្រី លន់ នល់ ការរៀបការខុសគ្នាឆ្ងាយណាស់ ព្រោះនៅទីនោះមានកូនកំលោះតែងតែទៅដណ្តឹងកូនក្រមុំ ទៅបញ្ជាក់ត្រឹមត្រូវមានឪពុកមានម្តាយ មាននំមាននែក មានបងប្អូន គគ្រឹកគគ្រេងមានខោអាវស្លៀកពាក់ដ៏ស្រស់ស្អាត មានអ្នកភ្លេង មានអ្នកហែហមការ មានបងប្អូនមកពិសាការ ឲ្យពរឲ្យជ័យ អួតសសើរពីបង១ដែលការជំនាន់មុនថា សមគ្នា អ៊ីចេះ អ៊ីចុះ អាចទំនងជាប្តីប្រពន្ធដ៏ល្អ ញញឹមញញែមដាក់គ្នា។ ចុះសម័យរបបប៉ុលពត របបខ្មែរក្រហម ដូចជាព្រៃផ្សៃណាស់ ចាប់បង្ខំឲ្យរៀបការចំពោះខ្ញុំវិញ ខ្លួនខ្ញុំតែម្តងគ្មានខោអាវស្លៀកទេ ខោអាវមួយកំប្លេប្រលាក់សុទ្ធតែដី ដាចទៀត ខោក៏ដាចអាវក៏ដាច កន្សែងក៏ដាច ខ្លួនក៏ស្គម ក្រឡេកទៅមើលជុំវិញ គ្មានបងប្អូនទេ មានតែមេកងឃោរឃៅចាំតែលើកដំបង ចាំតែលើកកាំបិតប្រហារជីវិត។

[១០:០៦:៥៤]

រួចសម័យមុនមានបងប្អូននៅជុំវិញឲ្យពរ ឲ្យជ័យ ញញឹមញញែម បើសម័យខ្មែរក្រហមមានតែ

01355124



ដំបង មានតែកាំបិត ចាំតែឲ្យតែធ្វើមិនត្រឹមត្រូវមិនដើរតាមអង្គការ កម្ទេចចោល។ ខុសគ្នាឆ្ងាយណាស់ លោកប្រធានអើយ ខុសគ្នាឆ្ងាយណាស់ ខ្ញុំមិនចង់បានរបបខ្មៅកខ្វក់ហ្នឹងមកទៀតទេ ស្អប់ណាស់។ អីក៏ឃោរឃៅម្ល៉េះ អាវក៏គ្មាន ខោក៏គ្មានប្រលាក់សុទ្ធតែដី កន្សែងដាច រកស្អីគ្មានទេ វេទនា។ អ្នកណាកើតមកចំសម័យនេះ សម័យតិរច្ឆានតែម្តង។ ខ្ញុំមកវេទនា វេទនាពេកកន្លងហើយ។ ឲ្យតែនឹកឃើញរឿងហ្នឹង ខ្ញុំចុកទ្រូង ឆ្អែតចិត្តណាស់ មែនណ៎ា យល់ឃើញអាររបបហ្នឹងមកក្តៅក្រហាយតែម្តង។ វាក្រហាយរហូតសព្វថ្ងៃ ខ្ញុំ សុខភាពក៏មានសាច់មានឈាម ប៉ុន្តែដូចជាអត់សប្បាយចិត្តសោះ ព្រោះកើតចំមកជីវិតឲ្យតម្លៃ សព្វថ្ងៃនេះ ថាជីវិតកើតមកសម័យតិរច្ឆានថោកទាបតែម្តង ធ្វើឲ្យខ្ញុំហូរទឹកភ្នែក។ អាពាហ៍-ពិពាហ៍ហ្នឹងៗ ដូចជា ដូចថាយើង គិតមើលទៅដូចពិបាកតែម្តង ដូចវាខ្វះ ខ្វះសេចក្តីស្រឡាញ់គ្នា បង្ខំឲ្យខ្ញុំជាសម្ភារៈ។ មេកង គេសុទ្ធតែទៅតាមគំនិតគេស្រួលៗ ហើយខ្ញុំជាប្រជាជនថ្មី គេតាមដាន។ គេឲ្យតម្លៃ ដូចវាថោកនោះ ថោកពេកហើយ វាគ្មានអីសោះ។ មានតែប៉ុណ្ណឹងទេ លោកប្រធានអើយ មានតែអាវដាច ខោដាច កន្សែងដាច ខ្លួនស្គម។ ហើយមកដល់សម័យនេះ ខ្ញុំចេះតែប្រឹងហូបចុកទៅ មានសាច់មានឈាមខ្លះ។ មានតែប៉ុណ្ណឹងទេលោកប្រធាន ខ្ញុំនិយាយទៅមុខមិនកើតទេ ឆ្អែតចិត្តណាស់ ព្រោះពិធីមង្គលការនេះវា ពីមុនមក ហើយមកដល់សម័យកាលឥឡូវនេះ ចូលដូចពីមុនវិញ ល្អណាស់។ ហើយអាសម័យ ៣ឆ្នាំ ៨ខែ ២០ថ្ងៃហ្នឹង តួអង្គខ្ញុំហ្នឹង ប្រេតតិរច្ឆានសុទ្ធតែម្តង រៀបការដូចប្រេតអីចឹង បើនិយាយឲ្យចំទៅ ប្រេតតិរច្ឆានសុទ្ធ ដែលការ ខោអាវក៏ដាច អាវក៏ដាច កន្សែងក៏ដាច សក់កន្ទ្រីងកន្ទ្រើង ភ្នែកសស្កុះ ស្គក់ដូចត្រីចង់ងាប់អីចឹង។ ជើងដៃស្គម មានតែឆ្អឹង មានស្បែកហ្នឹងដណ្តប់ឆ្អឹង។ ឃើញតែសសៃរវាម។ ហើយចេះតែប្រឹងធ្វើការទៅមិន ធ្វើម៉េចចង់រស់។ ខ្ញុំមានចម្លើយតែប៉ុណ្ណឹងទេ អស់ហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី។ ២០នាទី ចាប់ពីពេលនេះតទៅ។

*(សវនាការសម្រាកពីម៉ោង ១០:១០ នាទី ដល់ម៉ោង ១១:៣៥ នាទី)*

[១០:៣៥:២២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះបន្តសវនាការ។ មុននឹងបន្តសំណួរលើដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អង្គជំនុំជម្រះ

ប្រកាសសេចក្តីសម្រេចផ្ទាល់មាត់ពាក់ព័ន្ធនឹងសំណើរបស់មេធាវីការពារក្តីលោក ខៀវ សំផន ទាក់ទងទៅនឹងឯកសារ E327/4/5។ អង្គជំនុំជម្រះសូមបញ្ជាក់ថា អង្គជំនុំជម្រះអាចនឹងសម្រេចតាមការផ្តួចផ្តើមគំនិតរបស់ខ្លួនក្នុងការទទួលយកឯកសារខ្លះ ឬទាំងអស់ ដែលមាននៅក្នុងអនុស្សរណៈរបស់ខ្លួន។ អង្គជំនុំជម្រះអនុញ្ញាតតាមសំណើរបស់មេធាវីការពារក្តីលោក ខៀវ សំផន ដែលបានស្នើសុំពេលវេលាបន្ថែម។ ភាគីទាំងអស់ត្រូវដាក់ការកត់សម្គាល់របស់ខ្លួនទៅនឹងការទទួលយកឯកសារ ដែលមាននៅក្នុងអនុស្សារណនោះមុន ឬនៅថ្ងៃទី១៥ ខែកញ្ញា ២០១៦។ សេចក្តីសម្រេចនៅលើសំណើដែលនៅសេសសល់ និងសម្រេចក្នុងពេលឆាប់ៗខាងមុខនេះ។

សូមលោកមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីបន្តសំណួរ។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសូមសួរសំណួរបន្ថែមបន្តិចបន្តួចទៀត។ លោកបានពន្យល់អំពីពិធីរៀបការហ្នឹង តើលោកមាននៅចាំដែរឬទេ ថាតើអ្នកណា -- គូទាំង៥០គូហ្នឹង អ្នករៀបការទាំង៥០គូហ្នឹង ជាអ្នកណា អ្នកដែលរៀបការជាមួយលោក នៅថ្ងៃជាមួយគ្នាហ្នឹង? ខ្ញុំចង់សួរថា ពួកគាត់សុទ្ធតែមកពីកងចល័ត ឬក៏យ៉ាងណា តើលោកអាចនិយាយអំពីគាត់ទាំងអស់គ្នាហ្នឹងបានទេ?

[១០:៣៧:៤៣]

2-TCCP-232៖

**ឆ៖** បាទ សូមជម្រាបជូនលោកស្រីមេធាវី ទាំង៥០គូនេះ សុទ្ធតែពួកកងចល័តទាំងអស់ អត់មានពីណាមកចូលទេ សុទ្ធតែយុវជន និងយុវនារី ប៉ុន្តែសុទ្ធតែយុវជនក៏ចាស់ នារីក៏ចាស់ ប៉ុន្តែចាស់ស្អីត្រឹមអាយុ២៣, ២៤, ២៥ហ្នឹងចាស់ហើយ ព្រោះវាស្គមពេក នារីក៏ស្គម បុរសក៏ស្គមដែរ ស្គមដូចតែគ្នា។ អ៊ីចឹងបានថា៥០គូហ្នឹងមកនៅកងចល័ត។

**ស៖** តើមានអ្នកណាជំទាស់មិនព្រមរៀបការនៅថ្ងៃហ្នឹងដែរឬទេ?

**ឆ៖** បាទ មិនប៉ានទេៗ តែប៉ានជំទាស់គឺបាត់ខ្លួនហើយ អត់ប៉ានទេ។

**ស៖** លោកនិយាយពីពិធីរៀបការហ្នឹង លោកបាននិយាយថា ពួកគាត់ទាំងអស់ហ្នឹងសុទ្ធតែស្គមស្គាំង ខោអាវរហែករយ៉ៃ។ តើលោកអាចពិពណ៌នាអំពីបរិយាកាសក្នុងឱកាសរៀបការហ្នឹងដែរឬទេ? តើបុរស ហើយនិងនារីដែលរៀបការគ្នាថ្ងៃហ្នឹងៗគាត់មានទំនាក់ទំនងនឹងគ្នាយ៉ាងម៉េចដែរ?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01355126



[១០:៣៩:៣០]

**ឆ៖** បាទ សូមជម្រាបជូន។ នៅក្នុង៥០គូហ្នឹង ដូចខ្ញុំមិនបានដឹងថាមានបុរសនារីណា គេទាក់ទងគ្នា ខ្ញុំអត់ដឹងទេ ខ្ញុំអត់ដឹង។ គ្រាន់តែមានៗអ្នកខ្លះថាគូដណ្ដឹងគេ វាមានប្រវត្តិរូបគេល្អ គេតែខ្ញុំដល់រៀបការហើយបានដឹងកាលពីពេលកំពុងរៀបការ ខ្ញុំអត់បានដឹង ហើយខ្ញុំក៏គ្មានប៉ានដើរទំនាក់ទំនងគេ ព្រោះខ្ញុំអ្នកថ្មីប៉ានដើរទំនាក់ទំនងអ៊ីចឹង គេថាគិញហ្នឹងកុនទៀត រៀនសូត្រនឹងឧក្រិដ្ឋកម្មណាមួយមិនខាន។ អ៊ីចឹងខ្ញុំអត់ដឹងទេលោកមេធាវី។ សូមអរគុណ។

**ស៖** តើលោកអាចផ្ដល់ឈ្មោះ ហើយនិងព័ត៌មានលម្អិតអំពីប្រពន្ធលោក ហើយបុគ្គលដែលនឹងក្លាយជាប្រពន្ធលោកនោះ លោកអាចជម្រាបជូនពីព័ត៌មានលម្អិតអំពីគាត់បានដែរឬទេ? <តើគាត់ជាប្រជាជនថ្មីដែរមែនទេ?>

**ឆ៖** ខ្ញុំសូមជម្រាបជូនលោកស្រីមេធាវីថា ពេលដែលខ្ញុំកំពុងតែរៀបការ និងប្ដេជ្ញាហ្នឹង ខ្ញុំអត់ស្គាល់ទេ។ បើស្គាល់គ្នា ស្គាល់មុខគ្នា គឺនៅពេលដែលមេកងនារីហ្នឹង ឈ្មោះនារី ប៉ែត ហ្នឹងបាននាំយកមកជួបខ្ញុំនៅពេលព្រលប់ៗហ្នឹង ខ្ញុំបានឃើញគាត់។ ដល់ព្រឹកឡើង ភ្លឺច្បាស់ហ្នឹងបានយើងបានឃើញគាត់ស្គាល់គ្នាដែរ ប៉ុន្តែយើងចេញទៅធ្វើការរៀងៗខ្លួន ហូបបាយរៀងៗខ្លួន។ ក្រោយមកទៀត នៅប្រហែលយើងរៀបការបានប្រហែលជាមួយខែនៅក្នុងកងចល័តហ្នឹងបានប្រធានកង ពុត ហ្នឹងបានចេញលិខិតបង្គាប់ការបញ្ជូនខ្ញុំទៅកាន់ឃុំ កាន់ឃុំមួយ ឃុំហ្នឹងក្នុងឃុំអី ប៉ុន្តែទៅៗកងមុខ គេហៅភ្នួរនៅខាងកើតទីក្រុងតាកែវ។ កន្លែងហ្នឹងគេធ្វើស្រែប្រាំងហ្នឹង គេឲ្យខ្ញុំមានបីគូ។ បីគូមានជនជាតិចិនមួយគូនិងខ្មែរពីរគូ។ ជនជាតិចិននេះឈ្មោះ ទ្រី ហើយនិងនាង ហួយ ហើយមួយទៀតឈ្មោះ ជៀមៗ និងនាងប៊ិច ហើយខ្ញុំហ្នឹង និងគ្រួសារខ្ញុំទៅជួបមេឃុំ ដោយមាននីរសារគេនាំទៅ។ នីរសារគេថា កូនអង្គការមកបីនាក់អ៊ំ អ៊ំយកកូនអង្គការ អង្គការផ្ដល់ជូនមកអ៊ំហើយ។

[១០:៤១:៤៨]

អ៊ីចឹង មកដល់កន្លែងឃុំហ្នឹង មេឃុំឃើញបាយគាត់ហូបហើយសល់ពីបាយគាត់ហ្នឹងហូបហ្នឹងគាត់ថា “កូនអង្គការហូបបាយហ្នឹងទៅ!”។ ហូបបាយហើយ គាត់ឲ្យនីរសារគាត់ហ្នឹងជូនខ្ញុំបីគ្រួសារហ្នឹងទៅមានផ្ទះម្នាក់មួយ។ ផ្ទះហ្នឹងដូចគេមានអ្នកធ្វើស្រែប្រាំងហ្នឹង ប៉ុន្តែគេចែកឲ្យយើងមានតែគ្រែមានអី មានមាត់ទ្វារអីត្រឹមត្រូវដែរ។ ហើយខ្ញុំទៅរស់នៅទីនោះ។ ខ្ញុំនៅរស់នៅទីនោះ ក៏មានកងឈ្លបប្រចាំភូមិហ្នឹងគេចេញចូលឈ្លបរាល់យប់ យប់ណាក៏មានមកៗ។ ក៏ប៉ុន្តែរូបខ្ញុំហ្នឹងទៅដល់ទីនោះ មេឃុំ

ហ្នឹងចែកគោៗបាតក្រោល។ គោបាតក្រោល មកយើងនិយាយចំ គោហ្នឹងអស់ជម្រើសហើយ។ គោហ្នឹងស្គម ហើយនង្គ័លមួយគេចែកឲ្យទៅភ្ជួរ ហើយខ្ញុំបានគោហ្នឹងក៏អរហើយ ដឹកគោហ្នឹងឲ្យរកស្មៅ បោចស្មៅឲ្យវាស៊ី ខ្លាចដែរ គេឲ្យគោស្គមៗអ៊ីចឹងទៅ មិនដឹងរឿងម៉េចទៀត។ ក៏ខំរកស្មៅ រកអីហើយ ទីមគោហ្នឹងភ្ជួរស្រែជាមួយពួៗ កងសហករណ៍ហ្នឹងទៅ។ ហើយយើងចេះតែរស់នៅជាមួយគ្នាដូចជាបងប្អូនអ៊ីចឹង គ្រាន់តែប្រាប់គ្នាថា បើលោកមេឃុំ ឬប្រធានសហករណ៍គាត់សួរ យើងថាត្រូវនិយាយថា យើងស្រឡាញ់គ្នាណាស់ ដេកនៅជាមួយគ្នាត្រឹមត្រូវហើយ។ បើមិននិយាយអ៊ីចឹងទេ យើងទាំងពីរនាក់ប្រហែលជាមិនដឹងងាប់នៅគុម្ពោតណា ឬត្រង់កន្លែងណាទេ។ អ៊ីចឹង ខ្ញុំមកពីធ្វើការអស់កម្លាំងមានអ្នកនៅជិតហ្នឹងគេនិយាយថា ហ៊ឺ! មកនាំគ្នាប្តីប្រពន្ធទេ ដេកឲ្យលក់ឈឹង។ ចុះបើធ្វើការលំបាកសឹងអីមួយថ្ងៃៗ មិនមែនស្រណុកណា តាំងពីថ្ងៃរះរហូតដល់ថ្ងៃលិច ការងារមានរហូត។ បើមិនភ្ជួរស្រែ ក៏លើកភ្លឺស្រែផង ឲ្យគោស៊ីស្មៅផង អីផងសព្វបែបយ៉ាង។ អ៊ីចឹងអស់កម្លាំងណាស់ ហើយបាយតិចតួចទៀត មានតែហូបទឹកហើយផ្អែតអ៊ីចឹងទៅ នាំគ្នាដេកទៅ។ ព្រឹកឡើងយើងធ្វើការទៀត មានតែប៉ុណ្ណឹងទេ លោកមេធាវីលោកប្រធាន។ សូមអរគុណ។

[១០:៤៥:៥៩]

**ស៖** តើប្រពន្ធលោកឈ្មោះអ្វីដែរ? ហើយគាត់ហ្នឹងជាប្រជាជនថ្មីដែរ ឬក៏យ៉ាងណា?

**ឆ៖** បាទ ប្រពន្ធខ្ញុំហ្នឹងនាងគាត់ឈ្មោះ សុខ ខាត់ ជាប្រជាជនថ្មី អត់មានបងប្អូនអង្គការកម្ទេចទេ ត្រូវខ្មែរក្រហមកម្ទេចទេ បាទ។

**ស៖** សូមអរគុណ។ នៅក្នុងឯកសារ E3/5753 ជាភាសាបារាំងគឺ <00942172>, ជាភាសាខ្មែរ 00411856 ទៅដល់ 57, ជាភាសាអង់គ្លេសគឺ <00850851> គឺមានសរសេរថា លោករៀបការជាមួយមនុស្សម្នាក់ឈ្មោះ ចាន់ៗ។ តើលោកមានកំហុសនៅក្នុងឯកសារនេះ ឬក៏យ៉ាងម៉េច? ឬក៏ប្រពន្ធលោកហ្នឹង គាត់មានឈ្មោះហៅក្រៅថា ហៅ ចាន់ ដែរ?

**ឆ៖** បាទសុំជម្រាបជូន ឈ្មោះចាន់ ហ្នឹងមិនមែនជាឈ្មោះប្រពន្ធខ្ញុំទេ ប្រហែលជាការសរសេរហ្នឹងខុសទេ។ ប៉ុន្តែនៅក្នុងនុំងមានប្រធានកងមួយហ្នឹងឈ្មោះ ចាន់។ គាត់ច្រើនតែខ្នះខ្នែងជួយខ្ញុំ ណែនាំខ្ញុំថា មិត្តឯងត្រូវតែតាមអង្គការអ៊ីចឹងទៅ។ អ៊ីចឹងមានឈ្មោះ ចាន់ ហ្នឹងមិនមែនជាឈ្មោះអីទេ ជាឈ្មោះប្រធានកងទេ។ បាទ មានប៉ុណ្ណឹង។

[១០:៤៨:១២]

**ស៖** តើលោកជាប្ដីទី១របស់ប្រពន្ធលោកហ្នឹង? ឬក៏ប្រពន្ធលោក មុននឹងស្គាល់លោកហ្នឹង គាត់ធ្លាប់មានគូដណ្ដឹងដែរ មានធ្លាប់រួមរស់ជាមួយបុរសណាផ្សេងដែរ មុននឹងរៀបការជាមួយលោកហ្នឹង?

**ឆ៖** ពេលខ្ញុំរៀបការហើយ ខ្ញុំគ្រាន់តែដឹងថាប្រពន្ធខ្ញុំហ្នឹងជាអ្នកថ្មី ហើយឪពុកម្ដាយហ្នឹងស្លាប់បាត់អស់ហើយ អត់មានគូដណ្ដឹងអីណា អត់ទេ អត់មាន។

**ស៖** តើគេមានតាមដានលោកដែរឬទេ? គេមានមកលួចលបមើល ឬក៏លួចស្ដាប់អី ដើម្បីឱ្យដឹងថា តើលោករួមដំណេកឬអត់ ក្រោយពេលរៀបការហើយហ្នឹង?

**ឆ៖** ខ្ញុំសូមជម្រាបជូន កាលខ្ញុំនៅកងចល័ត ខ្ញុំរៀបការហើយ នារីប៉ែត ហ្នឹងបាននាំទៅជួបហ្នឹង ក៏មាននីរសាររបស់ រី, នីរសាររបស់ ពុត តែងតែមកឈ្លបជាប្រចាំ។ រហូតដល់ខ្ញុំចេញពីកងចល័តហ្នឹង ទៅនៅសហករណ៍ នៅខាងកើតងតាកែវហ្នឹង ក៏មានឈ្លបសហករណ៍ហ្នឹង គេតាមដានយើងទៀតដែរ ប៉ុន្តែហាក់ដូចជា គេតាមដានបានម្ដងពីរដងដែរ មានបងប្រុសម្នាក់ថា ហ៊ឺ! គ្នាមកពីអស់កម្លាំងចង់ងាប់ បានប្រព្រឹត្តអីទៅ រាងសុទ្ធតែឆ្អឹងអ៊ីចឹង ដើរវណ្ឌដើងគ្នាហើយទៅប្រព្រឹត្តយ៉ាងម៉េចទៅ។ អ៊ីចឹងអ្នកដែលគេនៅសហករខាងក្រោយនេះ គេមានសាច់ មានឈាម ដល់ឃើញខ្ញុំមកអ៊ីចឹងអ្នកនៅតាមសហករណ៍មានអ្នកថ្មី មានអ្នកចាស់អ៊ីចឹង គេតែងថាឱ្យខ្ញុំដែរ។ ប្អូនឯងខំរកអីហូបឱ្យបានច្រើនទៅឱ្យមានកម្លាំង។ ហើយខ្ញុំមិនដឹងទៅរកឯណាទេ ដើររកខុសបែបខុសបទហ្នឹង មានតែទៅព្យូរស្រែហ្នឹងចាប់បានកង្កែប ចាប់បានក្ដាមអីយកមកស្ងហូប មានតែប៉ុណ្ណឹងទេ។ មិនដឹងទៅរកស្អីក្រៅពីហ្នឹង រកក្រៅពីហ្នឹងខុសបែបបទ ប្រធានសហករហ្នឹងអាច ឬនាំឱ្យឈ្លបហ្នឹងចាប់យើងយកទៅអប់រំទៀត។ អ៊ីចឹងអត់អាចធ្វើអីបានទេ។ មានតែប៉ុណ្ណឹងលោកមេធាវី។

[១០:៥១:០៨]

**ស៖** សូមអរគុណ។ លោកបានឆ្លើយថាគេបង្ខំឱ្យលោករៀបការ ហើយលោកមិនស្រឡាញ់ប្រពន្ធលោកនោះទេ។ តើលោកមានព្យាយាមលែងលះដែរឬក៏អត់ ក្រោយពីរៀបការហើយហ្នឹង? ខ្ញុំនិយាយសំដៅនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យដដែល នៅសម័យហ្នឹងលោកមានព្យាយាមលែងលះគ្នាទេ?

**ឆ៖** បាទ និយាយឱ្យពិតត្រង់ទៅ នៅពេលហ្នឹងប្រសិនបើយើងសុទ្ធតែពេលកំពុងតែភ័យ នៅក្នុងរបបខ្មែរក្រហម គឺថាភ័យខ្លាច។ អ៊ីចឹងយើងត្រូវ គ្រាន់តែមាននិយាយថា យើងត្រូវនិយាយថា "ស្រឡាញ់គ្នា"។ អត់មាននិយាយថា បើសិនជានិយាយថារើបម្រះរកផ្លូវបែកគ្នាហ្នឹង អាហ្នឹងប្រហែល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជាបែកក្បាលទាំងពីរនាក់ហើយ មិនបែកក្បាលអីទេ បែកក្បាលគឺងាប់តែម្តង។ អ៊ីចឹងយើងអត់មានប៉ានចាលែងលះគ្នាទេ។ មានតែនិយាយគ្នាដោយស្រួល ដោយសន្តិវិធី ថាយើងស្រឡាញ់គ្នា យើងរស់ជាមួយគ្នាដោយស្រួល។ តែប៉ុណ្ណឹងអរគុណ។

[១០:៥២:៣២]

**ស៖** ខ្ញុំនៅសល់សំណួរពីរបីទៀតទេ។ តើលោកនៅជាមួយប្រពន្ធលោកដែរឬទេ ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យបានរំលត់ផុតទៅនោះគឺនៅឆ្នាំ១៩៧៩ ហើយក្រោយពីឆ្នាំ១៩៧៩ នោះលោកបែកបាក់គ្នាទេ ឬក៏នៅរួមរស់ជាមួយគាត់រហូត?

**ឆ៖** បាទ សូមជម្រាបជូនដោយត្រង់ថា ដល់ពេល៧៩នោះ សម័យនោះគឺជាថ្ងៃរំដោះហើយក្នុងគ្រួសារខ្ញុំនៅជួបជុំគ្នាបាត់តែឪពុក ហើយនិងបងប្អូនមាមីងមួយចំនួន។ អ៊ីចឹងនាងប្រពន្ធដែលរៀបការជាមួយខ្ញុំតែងតែតាមមកជាមួយបងប្អូនខ្ញុំ គ្រួសារខ្ញុំ និងរូបខ្ញុំ។ អ៊ីចឹងខ្ញុំអត់ទាន់មាន នៅតែជួបគ្នារហូត ហើយយើងក៏និយាយឲ្យចំទៅដល់ពេលនៅទីនោះយូរទៅដោយសម្គាល់ពីបងប្អូន ពីឪពុកម្តាយនិយាយលួងលោមខ្ញុំថា៖ "កូនអើយ! បងអើយ! បានជួបគ្នាហើយ យើងសុទ្ធតែកូនអ្នកមានពូជមានអំបូរ អ្នកកាន់សីលកាន់ទាន ប្រព្រឹត្តតែអំពើល្អ សាងតែកុសលល្អ កូនឯង បងឯងស្រឡាញ់គ្នាទៅ កុំពង្រាត់បង្រាស ហើយគាត់ជាក្មេងកំព្រា កូនកំព្រា គ្មានបង គ្មានប្អូនទេ ហើយយើងក៏កំព្រា យើងរស់នៅជាមួយគ្នាទៅ ដល់ចិត្តក្នុងការពិចារណាច្រើនថ្ងៃយូរថ្ងៃដែរទៅ ខ្ញុំក៏នឹកឃើញ ហើយឃើញប្រពន្ធខ្ញុំតែងតែប្រព្រឹត្តតែល្អៗជាមួយបងប្អូនខ្ញុំនិងរូបខ្ញុំ ខ្ញុំក៏មានការអាណិតស្រឡាញ់គាត់ទៅ ហើយក៏ស្រឡាញ់គ្នាហ្នឹងយើងក៏មានកូនចៅខ្លះដែរ។ ហើយមកដល់ក្រោយមកប្រពន្ធខ្ញុំក៏មានជំងឺឈឺ ជំងឺៗឈឺធ្ងន់ធ្ងរពេទ្យបានតែហៅខ្ញុំទៅបង្គាប់ថា លោកមិនអាចរស់នៅជាមួយគាត់បានទេ អ៊ីចឹងត្រូវតែឲ្យមើលឲ្យគាត់ជា ហើយរស់ជាមួយគាត់តទៅទៀតទៅ មិនអាចរស់ជាមួយគាត់ដូចមុនបានជាកូនជាចៅបានទៀតទេព្រោះគាត់មានជំងឺផ្សេងមួយ។ អ៊ីចឹងខ្ញុំសុំលាក់អត្តសញ្ញាណជំងឺផ្សេងនោះ។ អ៊ីចឹងខ្ញុំក៏សុំបែកគ្នាទៅៗ ហើយខ្ញុំក៏មានគ្រួសារមួយទៀតដែរ។ សូមជម្រាបជូន។

[១០:៥៥:៤៩]

**ស៖** សូមអរគុណ។ ខ្ញុំនៅសល់សំណួរចុងក្រោយ។ លោកក៏បាននិយាយអំពីគូដណ្តឹងរបស់លោក កាលពីព្រឹកមិញនេះ។ តើលោកមានដំណឹងអំពីគាត់ដែរឬទេ <ក្នុងពេលលោក>រៀបការ<នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬ>ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យចប់ទៅហ្នឹង លោកមានបាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទទួលដំណឹងអី ពីគូដណ្ដឹងលោកទេ?

**ឆ៖** ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យផុតរលត់បាត់ទៅ ខ្ញុំបានជួបគ្នា។ ជួបគ្នា ខ្ញុំចាប់ដៃគ្នា និងអោបគ្នាយំទល់មុខគ្នា។ ហើយយើងបានប្រាថ្នាថា "បងអើយ ជាតិនេះ យើងខំធ្វើបុណ្យទៅ។ ក្រែងយើងអកុសលពីជាតិមុន យើងមិនបានជួបគ្នា។ ចាំជាតិក្រោយ យើងជួបគ្នាទៅ។" យើងតែងតែជួបគ្នាតែងតែស្រក់ទឹកភ្នែកហូរហែ។ អ៊ីចឹងបានថាពិបាកណាស់លោកប្រធានអើយ លោកមេធាវី ព្រោះគូដណ្ដឹងនេះ វាយល់ចិត្តគ្នា ធ្លាប់ដើរលេងជាមួយគ្នា ធ្លាប់ជិះកង់ជាមួយគ្នា ធ្លាប់ដើរបុណ្យជាមួយគ្នា ធ្លាប់ប្រព្រឹត្តអំពើៗល្អជាមួយគ្នាថា នឹងបានជាគូគាប់ ក៏ប៉ុន្តែទៅបានជាគូអភ័ព្វទៅជួបឯណាឯណីនោះវិញ។ ដឹងគ្រាន់តែយើងជួបគ្នាហើយ គ្រាន់តែនិយាយល្អៗនឹងគ្នាទៅវិញទៅមក គ្រាន់តែប្រាប់គ្នាឲ្យធ្វើបុណ្យធ្វើទាន សាងកុសលទៅ ជាតិក្រោយ យើងមកជួបគ្នា។ មានតែប៉ុណ្ណឹងទេ។ សូមអរគុណ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំសូមអរគុណ លោកដើមបណ្ដឹងរដ្ឋប្បវេណី។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។ ហើយខ្ញុំសូមផ្ទេរវេទិកានេះ ទៅសហព្រះរាជអាជ្ញា លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី។

សូមអញ្ជើញលោកព្រះរាជអាជ្ញា មានសំណួរ ទៅដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

[១០:៥៨:០៤]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក គូមេន គេននី៖**

**ស៖** សូមអរគុណលោកប្រធាន។ ជម្រាបសួរ លោក លោកស្រីចៅក្រម ដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនសួរទៅលោក ក្នុងនាមឲ្យសហព្រះរាជាអាជ្ញា អំពីព្រឹត្តិការណ៍ និងបទពិសោធន៍មួយចំនួនដែលលោកជួបប្រទះ។ ខ្ញុំសូមសួរលោកអំពីការរៀបការរបស់លោកនៅក្នុងឆ្នាំ១៩៧៨។ ព្រឹកមិញនេះលោកបានជម្រាបអង្គជំនុំជម្រះថា មេកងរបស់លោកថា លោកមិនអាចរៀបការជាមួយនឹងសង្សាររបស់លោកទេ ពីព្រោះ<បងប្អូនប្រុស>របស់<សង្សារ>លោកហ្នឹង ត្រូវបានកម្ទេចចោល <ហើយមេកងនោះបានប្រើពាក្យថា "នៅពេលណាយើង>ដកស្មៅ <យើងត្រូវដកទាំងឫស។> តើលោកអាចជម្រាបជូនតុលាការបានទេ លោកយល់ដូចម្ដេចដែរ? គេមិនឲ្យលោករៀបការជាមួយ

01355131



សង្ស័យថា ដោយសារថា ដកៗគេដកស្មៅ ត្រូវដកទាំងឫស តើលោកយល់ដូចម្ដេច ចំពោះពាក្យនេះ?

[១០:៥៩:០៥]

2-TCCP-232៖

**ឆ៖** បាទ ខ្ញុំសូមជម្រាបជូនលោកថា មេកងគេនិយាយប្រាប់ហ្នឹង បើថាខ្ញុំនៅតែចង់បាននារីដែលមានបងប្រុសអង្គការកម្ទេចហ្នឹង ចោលហ្នឹង គឺគេមិនឲ្យរៀបការហ្នឹង គេថា កងហ្នឹងគេថា បើរៀបការជាមួយនារីរូបហ្នឹង ព្រោះបងបានកម្ទេចហើយ ក្រែងលោប្អូនហ្នឹង ប្អូនស្រីហ្នឹងរៀបការជាមិត្តឯងហ្នឹង កម្ទេចទាំងប្អូននិងមិត្តឯងហ្នឹងទៀត។ ហ្នឹងគេថាមួយពូជហ្នឹងគេចង់កម្ទេចឲ្យអស់ គឺចង់បោចស្មៅ បោចទាំងឫសឲ្យខ្ទេចហ្នឹង គេចង់ថាអ៊ីចឹងហើយលោកប្រធាន។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកក៏បាននិយាយផងដែរថា មេកងហ្នឹង បានគំរាមកំហែងមកថា នៅក្នុងតំបន់៣៣ហ្នឹង មានប្រជាជនត្រូវបានគេកម្ទេចចោលដោយសារតែមិនព្រមរៀបការតាមអង្គការ។ លោកដើមបណ្ដឹងរដ្ឋប្បវេណី ធ្វើម៉េចបានជាលោកដឹងថាមានរឿងនេះកើតឡើងនៅក្នុងតំបន់៣៣?

[១១:០០:៣៣]

**ឆ៖** បាទ សូមជម្រាបជូនលោក ប្រធានកង ពុត ជាប្រធានកងចល័តធំបំផុតនៅក្នុងស្រុក១០៧ហ្នឹងគឺស្រុកទ្រាំងហ្នឹងតែម្ដង។ គាត់និយាយលើកហេតុផលថា "មើលនេះ មិត្តឯងទាំងអស់គ្នា មើលឲ្យហើយ បើមិត្តណាដែលខ្ញុំជាកូនអង្គការហើយ ខ្ញុំរៀបការឲ្យ នារីហើយនិងបុរសហ្នឹងវាមាន សម្រស់ខុសគ្នា មិនស្អាតនិងមិនស្អាត ប្រយ័ត្នដូចតំបន់៣៣។ តំបន់៣៣ គឺខេត្តកំពង់ស្ពឺហ្នឹង នៅប្រាសាទភ្នំដាស្រុកអង្គរបូរីហ្នឹង ប្រធានកងហ្នឹង រៀបនារីស្អាតជាមួយនឹងបុរសមិនស្អាត។ បុរសមិនស្អាត រៀបជាមួយនារីស្អាត។ បុរសមិនចេះអក្សរ រៀបជាមួយនឹងនារីចេះអក្សរ។ នារីមិនចេះអក្សរ រៀបជាមួយនឹងបុរសមិនចេះអក្សរ។ ដល់ពេលនោះ អ្នកទាំងអស់ហ្នឹងគេអត់សប្បាយចិត្ត គេឡើងទៅបន់អ្នកតាភ្នំ។ ភ្នំបុរីហ្នឹងជាអ្នកតាស័ក្ដិសិទ្ធិណាស់។ អ៊ីចឹងបន់ថា នារីរូបស្អាត គេបន់ថា "ឲ្យប្ដីខ្ញុំងាប់ទៅ ខ្ញុំមិនស្រឡាញ់ទេ"។ ហើយប្រុសស្អាតនោះ គេទៅបន់ទៅថា "ឲ្យនាងហ្នឹងងាប់ទៅ"។ អ៊ីចឹងមេកងហ្នឹង គេដឹងគេយកទៅកម្ទេចចោលអស់ទៅ។ អាហ្នឹងបានថាសូមជម្រាបជូន មេកងពុត ហ្នឹងគេអ្នកលើកបញ្ហានេះ មកចង្អុលបង្ហាញប្រាប់ពួកខ្ញុំ៥០គូ។ បើប្រព្រឹត្តអ៊ីចឹងដែរ គឺគេកម្ទេចចោលដូចតំបន់៣៣ អ៊ីចឹងដែរ។

[១១:០២:២៨]

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកបានថា ខ្លួនលោកហ្នឹងបានរកឃើញមានលលាដ៍ក្បាលខ្មោច<នៅក្នុងព្រៃ>។ តើ<ព្រៃ>ហ្នឹង លោកដឹងទេថានៅកន្លែងណាដែរ?

**ឆ៖** បាទខ្ញុំដឹងលលាដ៍ក្បាលខ្មោចនេះ ពេលខ្ញុំទៅធ្វើទំនប់ប្រវត្តិសាស្ត្រ។ ទំនប់ប្រវត្តិសាស្ត្រហ្នឹង ខ្ញុំនិយាយជម្រាបជូនគឺ កាត់បឹងតែម្ដង កាត់ទន្លេតែម្ដង។ អ៊ីចឹងពីភ្នំបូរីមកអ៊ីចឹងមក មករហូតចេញមកត្បូងមក ប្រហែលជា បត់មកកំពង់អំពិល អាហ្នឹងស្រុកពីស្រុកអង្គរបូរី មកស្រុកបូរីជលសាវាលបឹងសុទ្ធ។ អ៊ីចឹងខ្ញុំបាន មេកងគេឲ្យខ្ញុំជីក -- រែកដី និងលើកជីកទំនប់ហ្នឹង បានសម្រេចសំណូមពរឲ្យខ្ញុំដើរបេះផ្លែឈូកផ្លែអីហូបទៅ ក៏ខ្ញុំធ្វើវាគ្រប់លក្ខណៈសម្បត្តិគេ គ្រប់គ្រាន់ឲ្យគេ ខ្ញុំដើរបេះទៅឃើញខាងកើតភ្នំហ្នឹង ពួកង -- ពួមិត្តនារីទៅរកឧសប្រាប់ថា បងឯងកុំដើរទៅលេងកន្លែងហ្នឹង ឃើញសុទ្ធតែឆ្អឹងខ្មោចច្រើនណាស់នៅខាងកើតភ្នំ។ អ៊ីចឹងនៅកន្លែងនោះ មានគេវៃចោលមនុស្សច្រើនដែរបាទ។ ខ្ញុំទៅឃើញ មើលពីចម្ងាយទេ ឃើញឆ្អឹងៗ សៗ ហ្នឹង លលាដ៍ក្បាលនៅគរនៅហ្នឹង ប៉ុន្តែខ្ញុំអត់ហ៊ានទៅជិតទៅជិតខ្លាចគេ មានគេតាមដានមកថា ខ្ញុំម៉េចៗ ថាខ្ញុំជាជនក្បត់ទៀត។ អ៊ីចឹងអាហ្នឹង នៅព្រំដែនវៀត-ណាមផង ជាប់ព្រំដែនវៀតណាមផង ទៅជីកប្រឡាយ និងទំនប់ហ្នឹង ខ្ញុំអត់ហ៊ានទៅជិតទេ។ ខ្ញុំថយមកវិញដោយស្ងាត់ស្ងៀម។ បាទ សូមជម្រាបជូនតែប៉ុណ្ណឹង។

**ស៖** លោកក៏បាននិយាយផងដែរថា លោកគិតថាលលាដ៍ក្បាលទាំងនេះ គឺជាលលាដ៍ក្បាលជនរងគ្រោះនៅក្នុងតំបន់៣៣ហើយ តើលោកអាចជម្រាបជូនតុលាការបានឬទេ ហេតុអីបានវាធ្វើឲ្យលោកគិតថាលលាដ៍ក្បាលហ្នឹងគឺជាលលាដ៍ក្បាលប្រជាជននៅតំបន់៣៣ ដែលគេសម្លាប់ចោលហើយ?

**ឆ៖** ខ្ញុំសូមជម្រាបជូនដែរថា លលាដ៍ក្បាលនេះ ខ្ញុំ -- ព្រោះខ្ញុំមិនបានឃើញ ឬក៏ គេវៃទេព្រោះខ្ញុំមិនបានដឹងទេ ប៉ុន្តែដល់លលាដ៍ក្បាលហ្នឹង យើងមើលពីចម្ងាយទៅឃើញវានៅគរមានឆ្អឹង មានលលាដ៍ក្បាលនៅពីចម្ងាយ។ ហើយបើដល់មេកង ពុត គេថាវៃចោលអ៊ីចឹង អាហ្នឹងខ្ញុំអាចសន្និដ្ឋានបានថា លលាដ៍ក្បាលពិតជាគេវៃចោលអ្នកនៅទីហ្នឹង។ មានតែប៉ុណ្ណឹងទេ លោក។

[១១:០៥:២៥]

**ស៖** សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ លោកក៏បានលើកឡើងផងដែរថា លោកបានប្រាប់ទៅប្រពន្ធរបស់លោកថា បើសិនអ្នកគេសួរប្រាប់ថា លោកនិងប្រពន្ធរបស់លោកហ្នឹង គឺថាស្រឡាញ់គ្នា។ តើចំណុចនេះ រាប់ទាំងការនិយាយប្រាប់គេតាំងពីរឿងការរួមភេទផង ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំនិយាយនេះ ខ្ញុំអត់បាននិយាយប្រាប់ដល់មនុស្សទូទៅទេ។ ខ្ញុំនិយាយតែពីនាក់គូ -- ពីរនាក់ប្ដីប្រពន្ធខ្ញុំដែលរៀបការហ្នឹងទេ បើមានគេសួរយើងពីរឿងការរួមភេទគ្នា ឬការនៅរស់នៅជាមួយគ្នា យើងត្រូវនិយាយ ប៉ុន្តែបើគេគ្មានសួរទេ យើងមិនបាច់និយាយទេ ប៉ុន្តែគ្រាន់តែយើងសម្ដែងលក្ខណៈយើងជាប្ដីប្រពន្ធឱ្យគេឃើញថាយើងស្រឡាញ់គ្នា។ មានតែប៉ុណ្ណឹងទេ ខ្ញុំមិនបានប្រាប់ ដើរប្រាប់ដល់មនុស្សដែលនៅក្បែរៗខ្ញុំហ្នឹងថាម៉េចៗទេ ប៉ុន្តែគេឃើញយើងខ្ញុំរាងស្គមអ៊ីចឹង ហើយឃើញទំនាក់ទំនងនិយាយគ្នា គេក៏អាចដឹងថាខ្ញុំហ្នឹងស្រឡាញ់គ្នាហើយ។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី តើវាមានកត្តាអ្វីដែល<>ធ្វើឱ្យលោកមានអារម្មណ៍ប្រាប់ទៅ<ប្រពន្ធ>លោកថា បើសិនណាជាមានអ្នកណាគេសួរពាក់ព័ន្ធ<នឹងការ>រួមភេទ <>លោកប្រាប់ប្រពន្ធលោកថា ត្រូវតែប្រាប់គេថាយើងស្រឡាញ់គ្នា រួមភេទជាមួយគ្នាមែន។ មានកត្តាអ្វីធ្វើឱ្យលោកមានអារម្មណ៍ប្រាប់ទៅប្រពន្ធលោកថាដូច្នេះ?

**ឆ៖** អាហ្នឹងងាយស្រួលជម្រាបជូនដែរ ព្រោះថា បើយើងមិននិយាយអ៊ីចឹង យើងប្រាប់គេថា អ៊ីចឹងមែនតែយើងហ្នឹង អត់ស្រឡាញ់គ្នា គេយកទៅសម្លាប់ចោលហើយ។ បើយើងប្រាប់គេថា យើងបានស្រឡាញ់គ្នា រួមភេទគ្នា រស់នៅជាមួយគ្នា សុខទុក្ខធម្មតា អាហ្នឹងយើងបានរួចខ្លួន។ បាទ និយាយឱ្យខ្លី។

[១១:០៧:៥៣]

**ស៖** លោកក៏បានលើកឡើងផងដែរថា ឈ្លបហ្នឹងគឺថាមកលបស្ដាប់រាល់យប់។ លោកដឹងទេថាតើការដែលឈ្លបគេមកលបស្ដាប់រាល់យប់ហ្នឹង គេមកលបស្ដាប់ចង់ដឹងថាលោកហ្នឹងមានរួមភេទជាមួយ<គ្នា>ដែរឬក៏អត់ទេ ឬក៏យ៉ាងណា?

**ឆ៖** បាទ មានឈ្លបមកមែន ប៉ុន្តែឈ្លបគេនៅឈរតែក្បែរខាងក្រៅហ្នឹង រួចផ្ទះយើងបិទជញ្ជាំងជិត មានទៅហែកជញ្ជាំងមើលអីណាឃើញ តែនាំមកដល់យើងដេកលក់អស់ទៅ ប៉ុន្តែមិនដែលឮគេនិយាយថាស្អីផង។ គ្រាន់តែគេមកក្បែរៗផ្ទះយើងហ្នឹង គេស្ដាប់អ៊ីចឹងហើយ គេទៅបាត់វិញទៅ។ មានតែប៉ុណ្ណឹង ប៉ុន្តែមិនឃើញ -- ឬអ្នកនៅជិតខាងហ្នឹងថា គ្នាមកអស់កម្លាំង ហើយរាងសម្គមអ៊ីចឹង ទៅធ្វើម៉េចទៅលោកអើយ។ អ៊ីចឹងបានថាពិបាកដែរ។ ខ្ញុំមិនដឹងឆ្លើយជូនលោកថាម៉េចទៀតទេ។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកបានលើកឡើងថា ប្រជាជនខ្លះគេអនុញ្ញាតឱ្យជ្រើសរើសដៃគូ ដែលគេស្រឡាញ់ហ្នឹងរៀបការជាមួយគ្នា។ ធ្វើម៉េចបានជាលោកដឹងថា មានប្រជាជនខ្លះត្រូវ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បានគេអនុញ្ញាតឲ្យជ្រើសរើសគូស្រករតាមចិត្តគេស្រឡាញ់ដែរ?

[១១:០៩:២៤]

**ឆ៖** បាទ សូមជម្រាបជូន អាហ្នឹងគឺថាគូរបស់គេ ប្រវត្តិរូបរបស់គេ ដូចថា ថ្មីអ៊ីចឹងអត់មានអង្គការកម្ទេច ខាងប្រុសហ្នឹងក៏ខាងកម្ទេច ខាងស្រីក៏អត់មានកម្ទេច ហើយជាគូដណ្តឹងគេ។ អាហ្នឹងគេល្អរបស់គេ គេបានទៅ។ បើសិនជាមានខាងប្រុសហ្នឹងមានអង្គការកម្ទេច ក៏គេមិនឲ្យរៀបដែរ។ អ៊ីចឹងបើសិនជាមានខាងប្រុសហ្នឹងកម្ទេច ខាងស្រីកម្ទេច អាហ្នឹងគេរៀបបាន អាហ្នឹងបានវិញ។ អាហ្នឹងវាជារឿងរបស់គេផ្សេង។ ខ្ញុំអត់បានតាមដានអារឿងគេថានយោបាយរបស់ប្រធានកងផង ហើយបើខ្ញុំអាល័យតែខ្លាចគេ ដូច្នេះខ្ញុំដឹងតែប៉ុណ្ណឹងលោក។

**ស៖** តាមដែលលោកដឹង តើជម្រើសដែលគេអនុញ្ញាតឲ្យថាប្រជា -- ជាគូស្រករខ្លះគេជ្រើសរើសអ្នកដែលខ្លួនស្រឡាញ់ទៅវិញទៅមកហ្នឹង គេអនុញ្ញាតឲ្យតែចំពោះបុរសទេ ឬក៏គេឲ្យស្ត្រីហ្នឹងមានជម្រើសអ៊ីចឹងដែរ មានសិទ្ធិជ្រើសរើស<អ្នក>ដែលខ្លួនស្រឡាញ់ដែរ?

**ឆ៖** អាការជ្រើសរើសស្រឡាញ់នេះ បើសិនជាគូគេ ដូចខ្ញុំនិយាយដដែលចុះ គេថាបើគូគេ ពីរនាក់ហ្នឹងអត់មានប្រវត្តិរូបហ្នឹងពាក់ព័ន្ធកម្ទេចគឺបាន។ ហើយបើសិនជាមានប្រវត្តិរូបហ្នឹងពាក់ព័ន្ធកម្ទេចគឺអត់បានទេ ចង់ម៉េចក៏មិនបានដែរ អត់បានជាដាច់ខាត។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ឥឡូវនេះខ្ញុំសូមទៅសួរលោកអំពីបទពិសោធន៍របស់លោក។ <លោកបានចូលរួម>ក្នុង<>របបខ្មែរក្រហម <ក្នុងឋានៈ>លោក<>ជាអតីតប៉ូលិសនៅក្នុងរបប លន់ នល់។ លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកមានដឹងថាខ្មែរក្រហមខិតខំប្រឹងប្រែងស្រាវជ្រាវរកអ្នកណាដែលធ្វើកិច្ច -- ជាអ្នករដ្ឋការក្នុងរបប លន់ នល់ ដែរទេ ដូចជាអ្នកណាធ្លាប់ធ្វើជាប៉ូលិស ធ្លាប់ធ្វើជាទាហានក្នុងរបប លន់ នល់ ដែរឬទេ?

[១១:១១:៥៩]

**ឆ៖** លោកសួរខ្ញុំ ហើយក៏សួរយ៉ាងម៉េច ខ្ញុំអត់យល់សំណួរហ្នឹងទេ។ សូមសួរម្តងទៀត។

**ស៖** បាទ ខ្ញុំសូមទោស លោកដើមបណ្តឹងរដ្ឋប្បវេណី។ ដោយសារតែខ្លួនលោកផ្ទាល់ជាអតីតប៉ូលិសរបប លន់ នល់ តើលោកមានបានឃើញ ឬក៏បានឮពីព្រឹត្តិការណ៍ណាមួយដែលខ្មែរក្រហមនេះប្រឹងប្រែងស្រាវជ្រាវ ដែកមុខរកអ្នកណាដែលធ្វើការក្នុងរបប លន់ នល់ ដូចជាធ្វើជាប៉ូលិស ធ្វើជាទាហានអីជាដើម លោកដឹងទេ?

**ឆ៖** បាទ កន្លែងហ្នឹងដឹង។ នៅក្នុង បើនិយាយក្នុងកងចល័តខ្ញុំ គឺថាមេកងហ្នឹងបានស្រាវជ្រាវតែម្ដង ស្រាវជ្រាវសួរ ហើយអ៊ីចឹងបើអ្នកណាដែលឆ្លើយរឿងពិតថាខ្លួនធ្វើប៉ូលិស ខ្លួនធ្វើទាហាន ហ្នឹងប្រវត្តិរូបគេសរសេរសួរបីដង។ ហើយមកនៅតាមភូមិទៀត ខ្ញុំក៏ដឹង គេស្រាវជ្រាវអ៊ីចឹងដូចគ្នា។ តែចំពោះរូបខ្ញុំមានអ្នកគេរាយការណ៍មកថាខ្ញុំហ្នឹងប៉ូលិសនៅទីក្រុងភ្នំពេញក្នុងរបប លន់ នល់។ អ៊ីចឹងមានអ្នកគេនិយាយមកខ្ញុំចំតែម្ដង ហើយខ្ញុំមានអារម្មណ៍ភ័យណាស់ ខ្ញុំឆ្លើយខ្លួនថាខ្ញុំមិនដែលធ្វើប៉ូលិសទេ ខ្ញុំជាសិស្ស ហើយខ្ញុំបួស មានតែប៉ុណ្ណឹង។ ហើយគេសួរខ្ញុំ អ៊ីចឹងបើមិត្តឯងបួស សូត្រធម៌ព្រះពុទ្ធឲ្យខ្ញុំស្ដាប់បន្តិចមើល អ៊ីចឹងខ្ញុំក៏សូត្រធម៌ឲ្យគេស្ដាប់ទៅ។ ហើយក្រោយមកមានបងស្រីម្នាក់ដែលជាមូលដ្ឋាន ហើយគាត់ជាប្រធានទៀត គាត់ប្រាប់ខ្ញុំថា ប្អូនៗតាំងពីខ្ញុំដឹងមក ដឹងតែប្អូនបួស ហើយនិងរៀនប៉ុណ្ណឹងទេ ប្អូនកុំឆ្លើយថាធ្វើប៉ូលិស ធ្វើប៉េអឹម ធ្វើទាហានអីឲ្យសោះ គេសម្លាប់នៅខាងមុខហ្នឹងហើយគេកម្ទេចចោលហើយ ឆ្នាំ៧៨ហ្នឹងគេកម្ទេចចោលហើយ អ៊ីចឹងប្អូនត្រូវឆ្លើយថាបួស ហើយនិងរៀនហ្នឹងទៅ ព្រោះបងដឹងប៉ុណ្ណឹង។ ហើយនៅក្នុងហ្នឹងមួយទៀត មានមេកងមួយទៀតឈ្មោះ ស៊ុក មេកងឈ្មោះស៊ុក ហ្នឹងនៅភូមិខ្ញុំដែរ មេកងហ្នឹងដឹងថាខ្ញុំតែបួស ហើយនិងរៀនតែប៉ុណ្ណឹង ប៉ុន្តែខ្ញុំមកធ្វើប៉ូលិសនៅភ្នំពេញនេះ អ្នកស្រុកអ្នកភូមិខ្ញុំគ្មាននរណាដឹងថាខ្ញុំធ្វើប៉ូលិសទេ។ អ៊ីចឹងខ្ញុំអាចលាក់អត្តសញ្ញាណប៉ូលិសហ្នឹងបាន ដោយមានបទពិសោធន៍ កាលខ្ញុំចេញពីភ្នំពេញទៅដល់កំពង់ចាមទៅស្នាក់នៅភូមិត្រពាំងស្នោខ្ញុំត្រូវជាប់នៅមន្ទីរឧក្រិដ្ឋកម្មវត្តផ្គាវនៅស្រុកហ្នឹង ប៉ុន្តែគេយកត្រឹមស័ក្តិ១ ស័ក្តិ២ រហូតដល់ស័ក្តិ៥ យកទៅសម្លាប់ចោលអស់ទៅ ចំណែកខ្ញុំប៉ូលិសតូចតាចកំប៉ិកកំប៉ុកហ្នឹងគេឲ្យរស់តាមភូមិ។ បើរស់តាមភូមិហ្នឹងបានបង ឡុង ស៊ីនួន ហ្នឹងគាត់ធ្វើមេអីឡូនៅផ្សារដើមថ្កូវយើងនេះ គាត់ប្រាប់ខ្ញុំថា អូនអើយកុំប្រាប់ថាធ្វើប៉ូលិស ហើយបងក៏មិនប្រាប់ថាស័ក្តិ៥ដែរ បងជាងមាស អូនឯងកម្មករលីកៅស៊ូ ព្រោះខ្ញុំមានអាវមួយស្អុយកៅស៊ូឲ្យហ្នួង។ អ៊ីចឹងខ្ញុំទៅធ្វើប័ណ្ណមួយទៀតនៅខាងភូមិត្រពាំងស្នោរហ្នឹង សុំគេដាក់លីកៅស៊ូទៅ គាត់ជាងមាសហ្នឹង ចេញរួចពីភូមិហ្នឹងទៅ។ បើសិនជាធ្វើប៉ូលិសក៏ចេញមិនរួចដែរ ស្លាប់នៅកំពង់ចាមហ្នឹងបាត់តាំងពីយូរហើយ។ អ៊ីចឹងការលម្អិតជូនមានតែប៉ុណ្ណឹងទេលោក សូមជម្រាបជូន។

[១១:១៥:៥០]

**សះ** លោកដើមបណ្ដឹងរដ្ឋប្បវេណីនៅស្រុកផ្គាវនោះ លោកក៏មាននិយាយថាមានគេសម្លាប់ទាហានដែលមានបណ្ដាស័ក្តិ ធ្វើម៉េចបានជាលោកដឹងថានៅទីនោះមានគេសម្លាប់ទាហានដែលមានបណ្ដាស័ក្តិ?

**ឆ៖** ខ្ញុំបានធ្វើសក្ខីកម្មលើកទី១ហើយៗ។ ខ្ញុំឃើញនឹងភ្នែកខ្ញុំតែម្តង ហើយសរសេរប្រវត្តិរូប ខ្ញុំក៏សរសេរខ្លួនខ្ញុំ បងៗស័ក្តិ១ ស័ក្តិ២ រហូតដល់ស័ក្តិ៥ ក៏សរសេរជាមួយខ្ញុំ អង្គុយមើលមុខគ្នាសរសេរហ្នឹងហើយ យកក្រដាសហ្នឹងទៅជូនមេនគរបាលខ្មែរក្រហមហ្នឹងទៅ ហើយដល់គេជ្រើសរើសយកត្រឹមស័ក្តិ១ ឌុបម៉ូតូចេញទៅៗខាងត្បូងភ្នំផ្ការបាត់ៗទៅ ហើយនៅសល់ប៉ុន្មានកូនទាហាន កូនប៉ូលិសអីហ្នឹងគេឱ្យទៅតាមភូមិទៅ។ ហើយក្រោយមក អាហ្នឹងខ្ញុំបានលាក់អត្តសញ្ញាណបានរស់ កន្លែងហ្នឹងខ្ញុំឃើញច្បាស់តែម្តង ច្បាស់នឹងភ្នែកខ្ញុំតែម្តង ឥឡូវនៅក៏នៅដែរអារម្មណ៍ក្នុងខួរក្បាលខ្ញុំក៏នៅឃើញ លោកស័ក្តិ៥ហ្នឹងឡើងបញ្ជាឱ្យយើងខ្ញុំឈរ បញ្ជានេះហ្នឹង ហើយគេឱ្យឡើងជិះម៉ូតូមកនាំម្នាក់ម៉ូតូប្រាំ ឌុបចេញៗអីចឹង ទៅរៀនសូត្រៗអីចឹង បាត់ងាប់អស់ទៅ។

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ នៅក្នុងសំណុំរឿង០០២/០១ ក៏លោកបានផ្តល់សក្ខីកម្មផងដែរ ឥឡូវនេះគឺថាលោកមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២/០២ នេះម្តងទៀត។ តើលោកអាចជម្រាបជូនតុលាការអំពីព្រឹត្តិការណ៍ដែលកើតទៅលើទាហានដែលមានបណ្តាស័ក្តិនេះ។តើគេធ្វើយ៉ាងម៉េចបានជាគេដឹងថាទាហានទាំងអស់ហ្នឹងមានបណ្តាស័ក្តិនេះមុនពេលគេស្រង់ប្រវត្តិរូបហ្នឹង?

[១១:១៧:៤៨]

**ឆ៖** ពេលខ្ញុំចេញពីភ្នំពេញទៅដល់ស្រុកផ្ការហ្នឹង បើយើងនិយាយទៅដូចជាសម្តីអ្នកឃោសនាអ្នកផ្សព្វផ្សាយខាងនយោបាយរបស់ខ្មែរក្រហមនិយាយពីរោះណាស់ ពីរោះមែន គួរឱ្យចង់ស្តាប់ គួរឱ្យចង់ស្រលាញ់។ និយាយប្រាប់ថា "បើបងប្អូនណាដែលធ្វើទាហានពាក់ស័ក្តិ១ ពាក់ស័ក្តិ២ ពាក់ស័ក្តិ៣ រហូតដល់ស័ក្តិ៥ ឥឡូវនេះ អង្គការត្រូវការបងប្អូនយកទៅបម្រើការងារវិញ ព្រោះខាងទ័ពមិនងាយបង្រៀនទេ ល្មមបានចេះដឹងផ្នែកខាងទ័ពមួយៗយូរណាស់។ អីចឹងសូមបងប្អូនឆ្លើយឱ្យច្បាស់ៗហើយនិយាយចំមក ហើយបងប្អូនណាធាក់ស៊ីក្លូតិចមកចង់ឆ្លើយថា ឯងស័ក្តិ៣ ស័ក្តិ៤ ស័ក្តិ៥ អ៊ូ ! អត់បានទេអាហ្នឹងរឿងហើយ គេយកទៅរៀនសូត្រនៅឆ្ងាយទៀត បើថាធាក់ស៊ីក្លូដឹងធាក់ស៊ីក្លូ បើកម្មករដឹងកម្មករ។

[១១:១៨:៥១]

អីចឹងការនិយាយឃោសនា លួងលោមរបស់មេក្រហមនៅទីនោះ ដូចជាសម្តីនោះផ្អែមណាស់ធ្វើឱ្យមនុស្សហ្នឹងជម្រាបជូនដោយស្មោះត្រង់ ប្រាប់ថាខ្ញុំស័ក្តិ១ ប្រាប់ថាខ្ញុំស័ក្តិ២ ប្រាប់ថាខ្ញុំប៉េអឹម។ មានលោកឪពុកមួយទៀត "ហា! កូនខ្ញុំប៉េអឹម កូនខ្ញុំធ្វើប៉េអឹម" ហើយប្អូនប្រុសហ្នឹងអត់បាននិយាយផង

ក៏តាមពាក្យឪពុកទៅ គេក៏ឃាត់ខ្លួននៅទីហ្នឹងទៅ។ អាហ្នឹងដោយការឃោសនារបស់គេ សម្ដីគេហ្នឹង វាផ្អែមល្ហែមណាស់ មុននឹងគេសម្លាប់ចោល ដូចគេនិយាយថា ដូចបង យន់ ប៊ិត គាត់និយាយថ្ងៃមុនថា "អង្គការសុំចងប្អូន ព្រោះអង្គការខ្លាចបងប្អូនអីចេះអីចុះ"។ បានជាឃោសនារបស់ខ្មែរក្រហម គឺអំពើអាក្រក់ខ្លាំងណាស់។ យកសម្ដី អាសម្ដីលាក់ពុតហ្នឹងយកមកបញ្ឆោតកុហកគេ យកគេទៅសម្លាប់បាត់ឃោរឃៅណាស់។ ហើយខ្ញុំចង់សុំប្រាប់លោកប្រធានថា សុំកុំឱ្យអារបបហ្នឹងកើតមកទៀត។ ខ្ញុំខ្ពើមណាស់ ខ្ពើមមួយជីវិតខ្ញុំ ខ្ពើមមិនចង់បានអារបបកខ្វក់ហ្នឹងមកទៀតទេ ស្អប់ណាស់។ វាគ្មានសីលធម៌ក្នុងខ្លួនទេ ជារបបនោះវាសុទ្ធតែជាអ្នកចេះដឹងខ្ពស់ៗមកសម្លាប់ជាតិឯង កាប់ក្បាលពូថៅ វ៉ៃត្បូងចប វ៉ៃឫស្សី រៀបការដោយបង្ខំ។ ត្រង់ខ្លួនឯងជ្រើសរើសនារីបានដ៏ល្អៗសម្រាប់ខ្លួនឯង មេកងមួយៗ ត្រង់កូនកងតូចៗជាសំរាមបាតជើងហ្នឹងឱ្យធ្វើតាមវេទនា ឱ្យបាក់បែកគ្នា ផ្ដាច់មនោសញ្ចេតនាគ្នា មិនឱ្យមនុស្សរស់ដោយស្រួលសោះ។ មានតែប៉ុណ្ណឹងទេ លោកប្រធាន។

[១១:២១:១០]

**ស៖** សូមអរគុណលោកបណ្ដឹងរដ្ឋប្បវេណី។ ឥឡូវខ្ញុំសូមសួរបន្តពីព្រឹត្តិការណ៍ពិសេសមួយនេះ និយាយអំពីការឃោសនារបស់ខ្មែរក្រហមដែលអំពាវនាវឱ្យអ្នកដែលមានបណ្ដាស័ក្តិហ្នឹងចូលខ្លួនមក ហើយអ្នកដែលមានបណ្ដាស័ក្តិលោកថាក៏ចូលមកប្រាប់គេតែម្ដងទៅ។ អ៊ីចឹងមកដល់ត្រង់ចំណុចដែលប្រាប់គេនេះ អ្នកដែលមានបណ្ដាស័ក្តិ គឺថាឆ្លើយប្រាប់គេថាតាមការឃោសនារបស់គេ បង្ហាញខ្លួន ហើយថាខ្លួនមានបណ្ដាស័ក្តិនៅក្នុងរបប លន់ នល់ ហ្នឹង។ អ៊ីចឹងមកដល់ត្រឹមហ្នឹង តើមានអ្វីកើតឡើងទៅដល់អ្នកទាំងនោះ?

**ឆ៖** អាហ្នឹងសូមជម្រាបជូនលោកដែរ ខ្ញុំបានធ្វើសក្ខីកម្មនៅលើកសំណុំរឿង០២/០១ ហើយ។ ក៏ប៉ុន្តែបើលោកសួរ ខ្ញុំជម្រាបជូនទៀត ព្រោះពេលដែលខ្ញុំទៅដល់ស្រុកផ្អាវហ្នឹង អាហ្នឹងគេហៅថាគណៈឃោសនាគេ។ គណៈឃោសនាគេនិយាយពីរោះណាស់ លោកប្រធានអើយ សម្ដីគេផ្អែមហ្នង ល្មមថាហើយពេលហ្នឹងគេអត់ទាន់មានបញ្ចេញចាប់មនុស្សឱ្យឃើញថាស្លាប់អី បើអ្នកដែលស្លាប់គេបាញ់គ្នាអាហ្នឹងស្លាប់បាញ់គ្នា។ ដល់ៗពេលនេះ គឺនិយាយដូចជាល្បួងលោម អង្វរករឱ្យមនុស្សឆ្លើយតែម្ដង។ និយាយផ្អែមណាស់ ផ្អែមពីរោះហ្នង។ ខ្ញុំក៏ស្ដាប់ដែរ ដឹងថា ហើយក៏ស្រឡាញ់ប្រទេសជាតិដែរថា ហ៊ា! ប្រទេសជាតិឥឡូវនេះកំពុងតែខ្វះខាតកងទ័ព អ៊ីចឹងសុំមិត្តដែលចេញមកពីទីក្រុង ដែលមានជំនាញចំណេះខាងអីៗហ្នឹងប្រាប់អង្គការឱ្យត្រង់ អង្គការរកការងារឱ្យធ្វើ ដាក់ឱ្យចំៗទិសដៅវិញ។ ចំទិសដៅ

ស្អី! យកទៅវ៉ៃចោលខ្ទេច។ អ៊ីចឹងបានតែថា ការឃោសនាហ្នឹងធ្វើឲ្យគាត់មានទឹកចិត្តស្នេហាជាតិ ស្រលាញ់ជាតិ ចង់ឲ្យប្រទេសជាតិហ្នឹងល្អ គាត់ឆ្លើយប្រាប់តែម្តងថា ខ្ញុំហ្នឹងស័ក្តិ១ ខ្ញុំហ្នឹងស័ក្តិ, ហើយខ្ញុំហ្នឹងស័ក្តិប៉ុន្មានៗអ៊ីចឹងទៅ ហូរហែគ្នា។ ដោយសារអី? ដោយសារការលួងលោមសម្តីដ៏ល្អ ហើយប្រាប់ថាប្រទេសជាតិកំពុងតែត្រូវការអ្នកចេះដឹង ហើយត្រូវការកងទ័ព។ អ៊ីចឹងគាត់ក៏ស្ម័គ្រចិត្តនិយាយប្រាប់អ៊ីចឹង បាទ។

[១១:២៣:៣៧]

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំសូមអរគុណច្រើនណាស់ដែលលោកបានឆ្លើយមកសំណួររបស់ខ្ញុំ ដែលលោកបានឆ្លើយនៅក្នុងសំណួរ០២/០១រួចមកហើយ។ បាទ រវាងអ្នកដែលឆ្លើយថាខ្លួនមានបណ្តាស័ក្តិនេះ មុនពេលគេយកអ្នកទាំងនោះទៅសម្លាប់ តើលោកដឹងទេថាមានអ្វីកើតឡើងទៅដល់អ្នកទាំងអស់នោះ មុនពេលគេយកទៅសម្លាប់?

**ឆ៖** មុនពេលយកគាត់ទៅសម្លាប់ គឺគេធ្វើប្រវត្តិរូបសរសេរហ្នុង ឲ្យគាត់សរសេរដោយខ្លួនឯង ហើយសរសេរខ្លួនឯងបញ្ជាក់ថា គាត់ពាក់ស័ក្តិប៉ុន្មានៗ ពីឆ្នាំណាដល់ឆ្នាំណា គេសួរអ៊ីចឹង ហើយនៅកងណា កងវរៈណា កងអីណា គេសួរអស់រលីង។ សួរហើយអ៊ីចឹង អ្នកដែលមកនិយាយជាមួយគ្នាហ្នឹង គេនិយាយទាំងញញឹមញញែម ល្មមតែយើងអត់ភ័យសោះហ្នឹង គឺស្រលាញ់ គឺពេញចិត្តនឹងចូលតែម្តង។ ហើយដល់ពេលអ្នកគេបើកម៉ូតូហ្នឹង ម៉ូតូប្រាំសេ.អិល។ សម័យហ្នឹងប្រើ សេ.អិល មកឌុប ក៏មានទឹកមុខញញឹមញញែម ហើយកងទ័ពខ្មែរក្រហមនៅកន្លែងនោះឲ្យច្រើនណាស់ មានអាវុធគ្រប់ដៃនៅទីហ្នឹង ក៏គេនិយាយនូវញញឹមញញែមទឹកស្រស់ស្រាយ ហើយមានអ្នកណាទៅភ័យអារម្មណ៍អីថាគេយកទៅរៀនសូត្រហ្នឹង យកទៅសម្លាប់ចោលទេ។ ឡើងជិះម៉ូតូកាន់វិទ្យុ កាន់អ្វីៗសៀវភៅ ប៊ិក អ៊ីចឹងយកទៅទាំងរីករាយ។ ប៉ុន្តែទៅបាត់ខាងត្បូងភ្នំ ភ្នំផ្ការហ្នឹងខាងត្បូងភ្នំ ទៅប្រហែល៥នាទីមកវិញៗអស់។ អ៊ីចឹងបើការសម្លាប់ហ្នឹងខ្ញុំដឹងដល់ពេលហ្នឹង នៅកងចល័តខ្ញុំនេះ។ ការកងចល័តខ្ញុំ ខ្ញុំមានគ្នា១០០នាក់ដែរ នៅសល់តែខ្ញុំមួយ ៩៩នាក់គេវ៉ៃចោលអស់ សល់តែខ្ញុំមួយ។ សល់ខ្ញុំមួយ ដែលខ្ញុំថាសិស្សហ្នឹង ក្រៅពីហ្នឹងគេយកវ៉ៃចោលអស់រលីង។ អ៊ីចឹងអ្នកដែលគេឌុបទៅអ៊ីចឹងគេកុហក គេប្រាប់ថា១០នាក់ ទៅចូកស្មៅអំពៅ ១០នាក់ទៅកាប់ឬស្សី ១០នាក់ទៅឡើងត្នោត ១០នាក់ទៅជួយកាប់ព្រៃ ទៅកាប់ព្រៃណាចូលមន្ទីរឧក្រិដ្ឋកម្មវត្តជើងចាបនៅក្បែរខេត្តតាកែវអស់រលីង។ គ្រាន់តែបានប៉ុន្មានថ្ងៃ គេបញ្ជូនខោអាវមកកងចល័ត ថា "អូ៎! មិត្តៗនេះស្លាប់អស់រលីង"។ អ៊ីចឹងបានថា ខ្ញុំៗថាបងប្អូនដែលស័ក្តិ៥ ស័ក្តិប៉ុន្មាន ស័ក្តិ១

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស័ក្តិ២ ស័ក្តិ៣ ស័ក្តិ៤ រហូតដល់ ស័ក្តិ៥ ហ្នឹងនៅផ្កាវហ្នឹង គឺគាត់ស្លាប់នៅក្នុងប្រហែលជាខែ៥ ឆ្នាំ៧៥ ហ្នឹងស្លាប់អស់។ រំដោះចេញពីភ្នំពេញទៅដល់ហ្នឹងមួយខែ ទៅស្លាប់អស់នៅទីហ្នឹង។ គ្មានទៅរៀនសូត្រឯណាទេ រៀនសូត្រក្នុងរណ្តៅអាបេ រណ្តៅអីហ្នឹងទាំងអស់នឹង។ បាទ សូមជម្រាបជូនប៉ុណ្ណឹង។

[១១:២៦:៥១]

**ស៖** សូមសួរបញ្ជាក់ចំណុចមួយលោកដើមបណ្តឹងរដ្ឋប្បវេណី។ <នៅពេលដែល>ទាហានប៉ូលិសដែលមានបណ្តាស័ក្តិនេះ<បំពេញប្រវត្តិរូបរបស់ពួកគេ> តើខ្លួនលោកផ្ទាល់នេះស្ថិតនៅក្នុងចំណោមអ្នកដែលទៅប្រាប់គេថាខ្លួនមានបណ្តាស័ក្តិហ្នឹងទេ? ខ្លួនលោកផ្ទាល់តើស្ថិតនៅក្នុងចំណោមអ្នកដែលបំពេញប្រវត្តិរូប ហើយប្រាប់គេថាខ្លួនមានបណ្តាស័ក្តិហ្នឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំក៏ប្រាប់គេដែរ។ ខ្ញុំប្រាប់គេថាខ្ញុំជាភ្នាក់ងារបម្រុងរាជការ ប៉ូលិសដែរ ប៉ុន្តែខ្ញុំភ្នាក់ងារបម្រុងរាជការ ប៉ុនខ្មែរក្រហមមិនដឹងខ្ញុំភ្នាក់ងារហ្នឹងស្អីផង។ គេសរសេរនៅលើឯកសារខ្ញុំវិញខ្ញុំសរសេរនៅហ្នឹងគេដាក់ខ្ញុំ ពលទោ អ៊ីចឹងពលទោ។ ហើយខ្ញុំសរសេរហ្នឹង សរសេរនៅក្នុងចំណោមពីស័ក្តិ១ រហូតដល់ ស័ក្តិ៥ ទាំងអស់គ្នាហ្នឹង មនុស្សច្រើនណាស់ មិនមែនមនុស្សតិចទេ។

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរបីបួនទៀតទេ។ តើនៅពេលនោះខ្លួនលោកផ្ទាល់មានបានបំពេញប្រវត្តិរូបឲ្យគេដែរឬទេ?

**ឆ៖** បាទ បានបំពេញៗ។

**ស៖** ហើយចុះនៅក្នុងប្រវត្តិរូបហ្នឹង លោកសរសេរថាដូចម្តេចដែរ? តើលោកសរសេរអ្វីខ្លះដែរអំពីមុខងារចាស់របស់លោកនេះ?

**ឆ៖** សរសេរៗថាខ្ញុំរៀន ខ្ញុំបួស រួចហើយខ្ញុំធ្វើជាភ្នាក់ងារបម្រុងរដ្ឋការលន់ នល់ និងប៉ូលិសដែរ ប៉ុនភ្នាក់ងារបម្រុង ពាក់បម្រុងរដ្ឋការលន់ នល់។ វាមានអាពាក្យបម្រុងហ្នឹងហើយដែលខ្ញុំបានរួចចេញពីហ្នឹង។ បើសិនជាអត់ដាក់បម្រុងទេ មិនដឹងទៅដល់ណា។

[១១:២៩:០៤]

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី នៅពេលដែលបំពេញប្រវត្តិរូបហ្នឹង តើវាមានចំណុចណាដែលៗនាំឲ្យលោកនឹកឃើញ ឬក៏វានាំឲ្យលោកមានវិញ្ញោចថា លោកត្រូវសរសេរប្រវត្តិរូបហ្នឹងកុហកអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ គ្មានកុហកអីទេ។ ខ្ញុំសរសេរត្រង់ៗតែម្តង។ គេប្រាប់ថាខ្ញុំភ្នាក់ងារបម្រុងរាជការ រដ្ឋ

ការ ធ្វើប៉ូលិសហ្នឹង ប៉ូលិសភ្នាក់ងារបម្រុងរដ្ឋការ មានតែប៉ុណ្ណឹង ខ្ញុំអត់មានកុហកអីសរសេរតាមរំញោចអីមិននឹកឃើញអីទេ សរសេរចំៗតែម្តង ព្រោះគេឃោសនាមកវាពីរោះពេកចូលត្រចៀកមកគួរតែស្តែងពាក្យសម្តីហ្នឹងប្រាប់គេឱ្យត្រង់តែម្តង។ ប្រាប់ខ្មែរក្រហមហ្នឹងត្រង់តែម្តង។

**ស៖** នេះគឺជាសំណួរចុងក្រោយលោកដើមបណ្តឹងរដ្ឋប្បវេណី។ តើលោកដឹងទេថា <តាមអ្វីដែលលោកបានឃើញ> បើសិនណាជាអ្នកណាបង្ហាញអត្តសញ្ញាណ<នៅក្នុងប្រវត្តិរូប ដោយ>ប្រាប់គេពីបុណ្យស័ក្តិរបស់<គេ នោះ>លទ្ធផលចុងក្រោយ គឺថាត្រូវបានគេនាំខ្លួនយកទៅបាត់។ តើលោកដឹងថា អ៊ីចឹងមែនឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបជូនលោកចំណុចពីរ ចំណុច--

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយ។ សូមអញ្ជើញលោកមេធាវី ខៀវ សំផន។

[១១:៣០:៤៣]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរចុងក្រោយនេះ ពីព្រោះវាជាប្រភេទសំណួរដែលឱ្យសាក្សីឆ្លើយដោយស្មាន។ លោកបញ្ជាក់អំពីស្ថានភាពមួយដែលមិនអាច ដែលមិនមានកើតឡើង ហើយក្នុងលក្ខខណ្ឌមួយថា ប្រសិនបើមានកាលៈទេសៈនោះ បាទ។ អ៊ីចឹងខ្ញុំសូមជំទាស់បាទ។ សូមអរគុណ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ប្រហែលជាមានបញ្ហាភាសាហើយ អ៊ីចឹងសូមរៀបសំណួរឡើងវិញ លោកសហព្រះរាជអាជ្ញារង។

**លោក កូមេន គេននី៖**

សូមអរគុណលោកស្រីចៅក្រម។

**សួរដោយលោក កូមេន គេននី៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី តើនេះជាការយល់របស់លោកឬដែលថា ខ្លឹមសារដែលគេសរសេរនៅក្នុងប្រវត្តិរូប អ្វីដែលលោកបានឃើញអ្នកដែលស្មោះត្រង់ ហើយសរសេរប្រវត្តិរូបខ្លួនដោយស្មោះត្រង់ប្រាប់អំពីតួនាទីរបស់លោកនៅក្នុងរបបលន់ នល់ តើលោកគិតថា ដោយសារតែអ្នកទាំងនោះ

សរសេរប្រវត្តិរូបដោយស្មោះត្រង់អ៊ីចឹងហើយហ្នឹង <> ទើបបានជាគេយកនាំខ្លួនចេញទៅបាត់អ៊ីចឹង ឬ?

[១១:៣១:៥៣]

**2-TCCP-232៖**

**ឆ៖** បាទ ការពិតអ៊ីចឹងមែន។ អ្នកសរសេរប្រវត្តិរូបហ្នឹង សម្តែងភាពស្មោះត្រង់ គេយកត្រឹមស័ក្តិ១ រហូតដល់ស័ក្តិ៥ យកទៅបាត់តែម្តង អាហ្នឹងនៅផ្សារ។ ហើយបើសិនជានៅ ខ្ញុំមកនៅតាកែវនេះវិញ បើសិនជាខ្ញុំសរសេរប្រវត្តិរូបថា ខ្ញុំធ្វើប៉ូលិស គឺខ្ញុំត្រូវស្លាប់បាត់ទៅហើយ។ បាទ ហ្នឹងសុំជម្រាបជូនប៉ុណ្ណឹង។

**លោក កូមេន គេននី៖**

សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ ឥឡូវដល់ពេលឈប់សម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ លោកដើមបណ្តឹងរដ្ឋប្បវេណី លោកអាចសម្រាកបានហើយ។ អង្គជំនុំជម្រះអញ្ជើញលោកមកកាន់ផ្តល់សក្ខីកម្មវិញ ឱ្យបានមុនម៉ោងមួយកន្លះរសៀលនេះ។

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឱ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១១:៣៣ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:៣០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តសវនាការ។ មុននេះបន្តិចអង្គជំនុំជម្រះបានទទួលអ៊ីម៉ែលពីសហព្រះរាជអាជ្ញាសុំធ្វើការកត់សម្គាល់ចំណាត់ថ្នាក់របស់សហចៅក្រមស៊ើបអង្កេតក្នុងការហៅដើមបណ្តឹងរដ្ឋ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្បវេណីជារហស្សនាម។ សូមអញ្ជើញលោកព្រះរាជអាជ្ញា ហើយឱ្យបានរយៈពេលខ្លី។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម មេធាវី ភាគីទាំងអស់។ សហព្រះរាជអាជ្ញាសូមបញ្ជាក់ឱ្យច្បាស់នៅក្នុងប្រតិចារឹក។ យើងជឿថា គ្មានមូលដ្ឋានណាមួយដែលមិនឱ្យដើមបណ្ដឹងរដ្ឋប្បវេណីប្រើឈ្មោះពិតទាំងស្រុងរបស់គាត់នោះទេ។ <តាមការយល់របស់>ខ្ញុំ <>សាក្សីគាត់<>មិនមានបញ្ហា<ក្នុងការផ្ដល់សក្ខីកម្មជាសាធារណៈនោះ>ទេ <ហើយក៏មិនមានបញ្ហាក្នុងការ>បង្ហាញឈ្មោះ<>ជាសាធារណៈនោះ<ដែរ។ បើគាត់បានជំទាស់ នោះខ្ញុំពិតជាយល់ស្របក្នុងការការពារមិនឱ្យបញ្ចេញឈ្មោះរបស់គាត់ ប៉ុន្តែតាមការយល់ឃើញរបស់ខ្ញុំ បុរសម្នាក់នេះមិនទាមទារឱ្យលាក់>អត្តសញ្ញាណរបស់គាត់<នោះទេ>។ ខ្ញុំយល់ ថាអង្គជំនុំជម្រះទទួលនូវលិខិតឆ្លើយឆ្លងនានា ក៏ប៉ុន្តែវាជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះក្នុងការសម្រេចអនុលោមតាមច្បាប់ ថាតើតាមការសន្មតនានា <សម្រាប់សវនាការសាធារណៈ គួរតែត្រូវបានបដិសេធចោលដោយបំណងល្អក្នុងការការពារសុវត្ថិភាព និង>ភាពឯកជន<របស់សាក្សីឬយ៉ាងណា។ តាមដែលយើងបានបញ្ជាក់ និងតាមដែលយើងបានដាក់ពាក្យស្នើសុំទៅអង្គជំនុំជម្រះ គឺថាសាក្សីនេះមិនត្រូវការការការពារពីសុវត្ថិភាព និងឯកជនភាពរបស់គាត់នោះទេ។ គាត់ស្ម័គ្រចិត្តផ្ដល់សក្ខីកម្មជាសាធារណៈ ហើយតាមគោលការណ៍របស់អង្គជំនុំជម្រះ ខ្ញុំគិតថា គ្រប់ដំណើរការនីតិវិធីទាំងអស់គួរតែធ្វើជាសាធារណៈ នេះគឺអ្វីដែលអង្គជំនុំជម្រះចង់បាន។ វាត្រូវតែរកឱ្យឃើញដោយ>អង្គជំនុំជម្រះ<នេះ ផ្អែកទៅលើមូលហេតុដែល>អង្គជំនុំជម្រះ<ដឹង ហើយឱ្យអនុញ្ញាតឱ្យធ្វើកំណត់ត្រាប្រតិចារឹក> ហើយចំពោះខ្ញុំ<>ជឿ និងដឹងថា ខាងសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីគាត់ក៏ឯកភាព ហើយមិនជំទាស់ទេ អ្វីដែលយើងខ្ញុំបានលើកឡើង។

[១៣:៣៦:០៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ បើគាត់មិនមែនជាសាក្សីទេ ជាដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសូមរំឭកថា សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី គឺមានឋានៈខុសគ្នានៅចំពោះមុខអង្គជំនុំជម្រះ។ បន្ទាប់មកទៀតយើងបានពិនិត្យមើលអនុស្សរណៈរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត និងចម្លើយរបស់អង្គជំនុំ

ជម្រះពាក់ព័ន្ធនឹងបញ្ហានៃការដាក់បង្ហាញឯកសារនៃសំណុំរឿង០៣, ០៤ ហើយនិងការចាត់ថ្នាក់ទៅលើឯកសារទាំងអស់នោះដែលបានស្នើឡើង។ ពាក់ព័ន្ធនឹងបញ្ហានេះ យើងយល់ថា ការិយាល័យសហចៅក្រមស៊ើបអង្កេតបានសុំឱ្យអង្គជំនុំជម្រះគោរពទៅតាមការចាត់ថ្នាក់នេះ ហើយភាគីអាចបញ្ចេញយោបល់ទៅលើការចាត់ថ្នាក់ខុសៗគ្នានេះ ហើយក្រោយពីមានការពិភាក្សាជាផ្ទាល់មាត់ អង្គជំនុំជម្រះបានប្រកាន់យកជំហរទៅតាមការកំណត់ចំណាត់ថ្នាក់របស់ការិយាល័យសហព្រះរាជអាជ្ញា -- សហចៅក្រមស៊ើបអង្កេត សូមអភ័យទោស។ ហើយអង្គជំនុំជម្រះទទួលយកលក្ខណៈវិនិច្ឆ័យរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឱ្យដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ផ្តល់សក្ខីកម្មដោយ -- ដែលហៅគាត់ជារហស្សនាម ដោយមិនត្រូវផ្តល់អត្តសញ្ញាណគាត់ជាសាធារណៈនោះទេ។ ដូច្នេះ <យើងគោរពតាមសេចក្តីសម្រេចរបស់អង្គជមនុំជម្រះ> ខ្ញុំសូមជម្រាបថាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មិនមានបញ្ហាអ្វីទេ បើអត្តសញ្ញាណគាត់ត្រូវបានបង្ហើបជាសាធារណៈនោះ ពីព្រោះថាគាត់បានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០១ រួចមកហើយ។ ដូច្នេះ សក្ខីកម្មរបស់គាត់ពេលនោះ គឺមានបង្ហោះនៅក្នុងអ៊ីនធើណេត វេបសាយរបស់អង្គជំនុំជម្រះ។ ដូច្នេះគាត់មិនមានការជំទាស់អ្វីទេ ក្នុងការបង្ហាញអត្តសញ្ញាណរបស់គាត់នោះ ហើយគាត់អាចផ្តល់សក្ខីកម្មដោយបង្ហាញឈ្មោះគាត់ពេញតែម្តង មិនចាំបាច់រក្សាការសម្ងាត់ លាក់បាំងអត្តសញ្ញាណអ្វីទេ។ ដូច្នេះ <គឺអាស្រ័យទៅលើ> អង្គជំនុំជម្រះ <ក្នុងការពិនិត្យមើលថាតើស្ថានភាពនេះស៊ីគ្នានឹងអ្វីដែលបានសម្រេច ពាក់ព័ន្ធនឹងការបង្ហាញឯកសារនៅក្នុង>សំណុំរឿង០០៣, ០០៤<ឬយ៉ាងណា>។

[១៣:៣៨:៣០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

**លោកស្រី ដូរីន ជិន៖**

ឱ្យខ្ញុំសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ឱ្យខ្ញុំឆ្លើយតបលោកប្រធាន?

ជាគោលការណ៍គឺ<យើងយល់ស្របថា រាល់នីតិវិធីគួរតែធ្វើជាសាធារណៈ។>

**ប្រធានអង្គជំនុំ៖**

ឱ្យលោកស្រីឆ្លើយតប។

**លោកស្រី ដូរីន ជិន៖**

ជាគោលការណ៍ឯកភាពទៅនឹងការផ្ដល់ជាសាធារណៈ។ ជាគោលការណ៍យើងខ្ញុំយល់ឃើញថា កិច្ចដំណើរការនីតិវិធីទាំងឡាយគួរតែធ្វើឡើងជាសាធារណៈ។ យើងខ្ញុំពុំមានការកត់សម្គាល់អ្វីក្រៅពីនេះនោះទេ។

[១៣:៣៩:១៥]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជូនការកត់សម្គាល់ថា សាធារណភាពនៃដំណើរការសវនាការគឺវាជាការចាំបាច់សម្រាប់ដំណើរការស្វែងរកយុត្តិធម៌។ ហើយដោយឡែក ខ្ញុំក៏បានសង្កេតឃើញចំពោះដើមបណ្ដឹងរដ្ឋប្បវេណីដែលមានវត្តមាននៅទីនេះ ហើយគាត់មានមេធាវីរបស់គាត់ជាអ្នកការពារសិទ្ធិ ឬក៏ពិនិត្យទៅលើនីតិវិធីឲ្យដំបូន្មានច្បាប់ផ្សេងៗ។ ដូច្នេះ បញ្ហាដែលអាចប៉ះពាល់នៅក្នុងការថ្លែងជាសាធារណៈនៅទីនេះវាអាចកាត់បន្ថយ ឬក៏ត្រួតពិនិត្យបានដោយមេធាវីរបស់គាត់។ ដូច្នេះ បើសិនជាដើមបណ្ដឹងរដ្ឋប្បវេណីមានបំណងចង់បង្ហាញនូវដំណើរការសាធារណភាពនៃដំណើរការសវ-នាការនៅទីនេះ គឺមិនមានអ្វីដែលគួរឲ្យបារម្ភទេ ហើយដោយឡែកចំពោះឋានៈខុសគ្នារវាងដើមបណ្ដឹងរដ្ឋប្បវេណី និង សាក្សី គឺអាចបញ្ជាក់អំពីភាពចាំបាច់ខុសគ្នាផងដែរនៅក្នុងចំណុចនេះ។ ដូច្នេះ សូមអង្គជំនុំជម្រះអានពិចារណាទៅលើសំណើនេះបានបាទ។ សូមអរគុណ។

[១៣:៤០:៣៤]

**ប្រធានអង្គជំនុំ៖**

សូមប្រគល់វេទិកាទៅលោកចៅក្រម ហ្សង់ម៉ាក។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ ជាដំបូងខ្ញុំសូមធ្វើការកត់សម្គាល់មួយចំនួន។ យើងយល់ច្បាស់ហើយថាសវនាការនេះជាសាធារណៈ យើងមានសាធារណជនស្ដាប់ ក៏ប៉ុន្តែបញ្ហារបស់សហព្រះរាជអាជ្ញាលើកឡើងហ្នឹង គឺការប្រើប្រាស់រហស្សនាម។ ខ្ញុំដឹងថា បញ្ហានេះ គឺវា ខ្ញុំវាមានលក្ខណៈឆ្ងល់ដែរ មកដល់ដំណាក់កាលនេះហើយ ហេតុអីបានជាយើងលើកបញ្ហាហ្នឹង ទើបតែនៅពេលហ្នឹង។ លក្ខខណ្ឌនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ឬសាក្សីដែលពាក់ព័ន្ធនឹងការដាក់បង្ហាញឯកសារមកពីសំណុំរឿង០០៣, ០០៤នោះ ត្រូវដឹងច្បាស់តាំងពីពេលដែលសហចៅក្រមស៊ើបអង្កេតចេញសេចក្ដី

សម្រេចកំណត់អំពីលក្ខខណ្ឌនៃការស្តាប់ចម្លើយសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធរួចមកហើយ។ ដូច្នេះ តាំងពីដំបូងមកម្ល៉េះ យើងដឹងបាត់ទៅហើយថាដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង នឹងត្រូវផ្តល់សក្ខីកម្ម ដោយប្រើរហស្សនាម ឬក៏ប្រើឈ្មោះពិតនោះ។

[១៣:៤១:៥៩]

ចំណុចទី២ លក្ខខណ្ឌទាំងអស់នេះ ត្រូវបានកំណត់មិនមែនតែក្នុងលក្ខខណ្ឌដើម្បីចាត់វិធានការ ការពារសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនិងសាក្សីហ្នឹងប៉ុណ្ណោះទេ គឺវាជាការរក្សានូវការសម្ងាត់ ឬក៏ សុចរិតភាពនៃការស៊ើបអង្កេត។ យើងបានសម្រេចថា វិធានការទាំងអស់នេះ វាអាស្រ័យទៅលើសហ ចៅក្រមស៊ើបអង្កេត ហើយអង្គជំនុំជម្រះនឹងមិនមានការកែប្រែអ្វីទេ។ អ៊ីចឹងបញ្ហា ខ្ញុំចង់សួរថា តើ ការិយាល័យសហព្រះរាជអាជ្ញា ឬភាគីផ្សេងទៀត បានធ្វើការកត់សម្គាល់ទៅកាន់សហចៅក្រមស៊ើប អង្កេតហើយឬនៅ? ហើយប្រសិនជាបានធ្វើហើយនោះ តើធ្វើនៅពេលណា <ហើយហេតុអ្វីបានជាមិន ឃើញមានរហស្សនាម? នៅ>ដំណាក់កាលនេះ <តើវាសមរម្យសម្រាប់ឲ្យ>អង្គជំនុំជម្រះ<ពិចារណា លើសំណួរនេះទេ?>

**លោក នីកូឡាស គូមជែន៖**

បាទ ចំណុចនេះ គឺលោកចៅក្រមលើកឡើងក្នុងក្របខ័ណ្ឌបានត្រឹមត្រូវ។ តាមខ្ញុំចាំ គឺយើងបាន លើកឡើងបញ្ហានេះរួចមកហើយ ហើយយើងមិនបានស្នើសុំឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត យើងប្រើប្រាស់នូវរហស្សនាមនោះទេ។ ខ្ញុំ<ក៏>បានលើកឡើង<ទាក់ទងទៅនឹង>វេលា<ផងដែរ ខ្ញុំគិត ថា បញ្ហានេះមិនមែនជាអ្វី>ដែលចៅក្រមស៊ើបអង្កេត<>សម្រេច<នោះទេ ប៉ុន្តែជាអ្វីដែលចៅក្រមអង្គ ជំនុំជម្រះយើងនេះជាអ្នកសម្រេច ដោយផ្អែកទៅលើ>ហេតុផលចំនួនពីរ។ ទី១ អង្គបុរេជំនុំជម្រះបាន សម្រេចយ៉ាងច្បាស់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន D309/6 – D309/6 គឺពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញា លើសេចក្តីសម្រេចមុនៗរបស់សហចៅក្រមស៊ើបអង្កេត <ដែល>សហចៅក្រម ស៊ើបអង្កេតមិនអាចដាក់លក្ខខណ្ឌដែលវាប៉ះពាល់ទៅដល់គោលការណ៍សាធារណៈនៃការជំនុំជម្រះនោះ ទេ។ វាអាស្រ័យទៅលើអង្គជំនុំជម្រះ សាលាដំបូងជាអ្នកសម្រេចនៅពេលដែលកិច្ចដំណើរការនីតិវិធីធ្វើ ដំណើរការទៅមុខ។ <ជាការពិតហើយ គេអាចស្នើសុំដោយមានហេតុផល។>

[១៣:៤៤:០៦]

ចំពោះ<>ការដែលយើងប្តឹង<ពីបញ្ហា>រហស្សនាម<ទៅ>សហចៅក្រមស៊ើបអង្កេតនោះ

<មូលហេតុមួយទៀត គឺ>វាមិនសមរម្យទេ <គឺភាគីភាគច្រើន ឬក៏ពាក់កណ្តាលនៃកិច្ចដំណើរការនីតិវិធីនេះមិនមានវត្តមាន>។ មេធាវីការពារក្តី ខៀវ សំផន និង នួន ជា ហើយនិងសហមេធាវីនាំមុខនោះគាត់នៅក្នុង -- ជាភាគីនៅក្នុងសំណុំរឿងនេះ មិនមែនសំណុំរឿង<ផ្សេងណា>នោះ<>ទេ។ <ហើយទី៣ ខ្ញុំគិតថា នេះជាពេលវេលាសមស្រប ព្រោះថាបញ្ហា>សំខាន់ចំពោះយើងខ្ញុំ គឺ<អ្វីដែលសាក្សីនេះ --> ខ្ញុំអធ្យាស្រ័យដែលខ្ញុំប្រើថាគាត់ជាសាក្សី។ វាសំខាន់ដែលថាដើមបណ្តឹងរដ្ឋប្បវេណីនេះ មកផ្តល់សក្ខីកម្មនៅទីនេះ <គាត់ចង់ធ្វើបែបនេះ។ បើគាត់មកទីនេះ> ហើយគាត់បានលើកឡើងថា ដោយសារតែលក្ខណៈ<កំហិតនៃអ្វី>ដែលគាត់លើកឡើងឆ្លើយតបនោះ <គឺ>គាត់ចង់រក្សានូវការសម្ងាត់។ <ខ្ញុំពិតជាយល់ និងគាំទ្រដោយពេញទំហឹងចំពោះ>សេចក្តីសម្រេចរបស់គាត់ <ក៏ដូចជាជនរងគ្រោះផ្សេងទៀត។> ក៏ប៉ុន្តែប្រសិនបើសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីមកទីនេះឆ្លើយថាគាត់មិនខ្លាចទេ គាត់អាចលាតត្រដាងនូវឈ្មោះពេញលេញរបស់គាត់ <យើងក៏គាំទ្រសេចក្តីសម្រេចនោះ> ហើយ<យើងគិតដល់ផលប្រយោជន៍របស់តុលាការ ផលប្រយោជន៍សាធារណៈ និងប្រវត្តិសាស្ត្រ>។

[១៣:៤៥:០៧]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមធ្វើការលើកឡើងទៅលើចំណុចនេះ។ ការយល់ឃើញរបស់យើងទាំងអស់គ្នាគឺថា សហចៅក្រមស៊ើបអង្កេតស្នើសុំឲ្យអនុវត្តវិធានការនេះ វាមិនមែនតែទៅលើវិធានការការពារទៅលើសាក្សីប៉ុណ្ណោះនោះទេ ការដែលស្នើអ៊ីចឹងនេះ គឺដើម្បីធានានូវភាពសម្ងាត់ ឬសុចរិតភាពនៃការស៊ើបសួរ។ យើងមិនដឹងថាតើប្រើប្រាស់ឈ្មោះ ឬក៏មិនប្រើប្រាស់ឈ្មោះនោះ វាប៉ះពាល់ទៅដល់ការរក្សាការសម្ងាត់យ៉ាងម៉េចទៅដល់សហចៅក្រមស៊ើបអង្កេត ឬកិច្ចស៊ើបសួររបស់គាត់នោះទេ យើងអត់ដឹងទេ ដោយសារគេស្នើអ៊ីចឹង។ លោកបានលើកឡើងហើយសេចក្តីសម្រេចរបស់ចៅក្រមស៊ើប -- សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើសហចៅក្រមស៊ើបអង្កេត ដែលលើកឡើងថា <សំណើទាំងអស់នេះគ្មានតម្លៃហើយមិនសំខាន់។ ដូច្នេះ សូមអាន>សេចក្តីសម្រេច<>នោះ <ហើយចាប់ផ្តើមការពិភាក្សាចាប់ពីចំណុចនោះមក។> ក៏ប៉ុន្តែ<ជាថ្មីម្តងទៀត វាមិនមែនជាបញ្ហា>វិធានការ<ការពារនោះទេ ពិតប្រាកដណាស់ យើងដឹងពីច្បាប់នេះ ក៏ប៉ុន្តែ> គឺដើម្បីជាការធានានូវសុចរិតភាពនៃការស៊ើបអង្កេត ឬការរក្សាការសម្ងាត់។

[១៣:៤៦:១១]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក នីកូឡាស គូមជែន៖**

ចំណុចនេះគឺជាចំណុចមួយស្របច្បាប់។ <សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ដែលចេញដោយ> អង្គបុរេជំនុំជម្រះ<> មិនមែនថាច្រានចោលទាំងស្រុង គ្រវាត់ចេញតាមបង្ហួចនៅលើ -- ទៅលើសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបអង្កេតនោះទេ ក៏ប៉ុន្តែ<និយាយថា គេគ្មានការកំហិត។ មានការឲ្យយោបល់ថា វាអាស្រ័យទៅលើចៅក្រម>អង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះ ដូច្នេះហើយគឺអង្គជំនុំជម្រះសាលាដំបូង ប្រសិនបើយើងឃើញថាសមស្របនោះ អាចធ្វើការច្រានចោល ហើយគិតអំពីអត្ថិភាពនៃគោលការណ៍សាធារណៈនៃការជំនុំជម្រះ។ ហើយដោយសារតែយើងដឹងហើយថាសាក្សីរូបនេះ ឬដើមបណ្ដឹងរដ្ឋប្បវេណីគ្មានសារៈសំខាន់ ហើយការលាតត្រដាងឈ្មោះគាត់នោះ មិនប៉ះពាល់ដល់សុចរិតភាពនៃកិច្ចស៊ើបសួរនោះទេ ដូច្នេះដោយស្មោះត្រង់ទៅ ខ្ញុំគិតថាសេចក្ដីសម្រេចដែលអង្គជំនុំជម្រះសាលាដំបូងបង្ហាញហេតុផលទៅលើបញ្ហានេះនោះ វាមិនមែនថាវាត្រូវទាំងអស់សម្រាប់ជាមូលដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចនោះទេ គ្រាន់តែកាតព្វកិច្ចរបស់ចៅក្រមស៊ើបអង្កេតនោះ គឺថាមានកាតព្វកិច្ចត្រូវបង្ហាញនូវហេតុផលតែប៉ុណ្ណោះ ហើយជាពិសេស ខ្ញុំលើកឡើងអំពីឯកសារ <D309/6>។

[១៣:៤៧:៣៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្ដីលោក នួន ជា បន្តសំណួរលើដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ បាទ សូមអញ្ជើញ!

**លោកស្រី ដូរីន ជិន៖**

លោកប្រធាន យើងខ្ញុំអត់មានសំណួរចង់សួរដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខាងក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន អត់មានសំណួរដែរ បាទ សូមអរគុណ។

[១៣:៤៨:១៩]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

លោកដើមបណ្តឹងរដ្ឋប្បវេណី ក្នុងឋានៈលោកជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការស្តាប់អំពីរឿងហេតុទំនាក់ទំនង ទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទទាំងពីររូប លោក នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ និងអំពីស្ថានភាពព្យសនកម្ម និងការខូចខាតដែលកើតមានឡើងចំពោះលោក ជាអាទិ៍ខូចខាតខាងរាងកាយ សម្ភារៈ ឬក៏ផ្លូវចិត្ត ហើយជាផលប៉ះពាល់ផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋ ព្យសនកម្មផ្ទាល់ខ្លួន និងបានកើតមានឡើងពិតប្រាកដរហូតដល់បច្ចុប្បន្ននេះ ដែលនាំឱ្យលោកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារសំណង និងជាសមូហភាពពីជនជាប់ចោទ។ បើសិនជាលោកមានបំណងដូច្នេះ គឺលោកអាចថ្លែងរៀបរាប់ពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មចំពោះមុខអង្គជំនុំជម្រះបាន ឬអាចតាំងសំណួរទៅកាន់ជនជាប់ចោទបានតាមរយៈអង្គជំនុំជម្រះ។ សូមអញ្ជើញ!

[១៣:៤៩:៥០]

**2-TCCP-232៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំនៅឆ្នាំ៧៥ ខ្ញុំធ្វើជាមន្ត្រីប៉ូលិសនៅទីក្រុងភ្នំពេញ ខ្ញុំសង្ឃឹមថាខ្ញុំនឹងបានធ្វើជាប៉ូលិសបម្រើប្រទេសជាតិ។ បែរជាមិនបានធ្វើ ត្រូវមានការដេញចេញនៅថ្ងៃទី១៧ មេសា ៧៥ ចេញពីភ្នំពេញ។ ភាពវេទនារបស់ខ្ញុំមានច្រើនណាស់ ចាកចេញពីភ្នំពេញទៅ គឺថាភាពវេទនារបស់របស់ខ្ញុំដើរដេកតាមផ្លូវ គ្មានបាយហូប និងគ្មានអ្វីហូបចុកទេ។ ដល់តែពេលឃើ ធ្លាក់ខ្លួនឈឺនៅខេត្តកំពង់ចាម ខ្ញុំគ្រុនក្តៅរងាអត់មានថ្នាំលេបទេ គឺខ្ញុំដើរបេះស្លឹកស្តៅយកមកបុក ហើយដាក់ទឹកទៅ យើងហូបទាំងទឹកទាំងកាក។ ហើយបានធ្វើដំណើរទៅទៀត ទៅដល់ផ្ការហ្នឹង បានចូលទៅកន្លែងមន្ទីររបស់កងទ័ពស្រុកផ្ការហ្នឹង កងទ័ពខ្មែរក្រហមស្រុកផ្ការហ្នឹង គេបានចាប់ខ្ញុំចូលទៅក្នុងនុំង ដោយ-សារខ្ញុំជាប៉ូលិស។ នៅទីនោះគេហ៊ុមព័ទ្ធជុំវិញ។ ទីនោះមានអ្នកយាមជាកងទ័ពខ្មែរក្រហមព័ទ្ធវិញជាពីរបីជាន់នោះ មិនឱ្យយើងចេញទៅណា គេឱ្យធ្វើប្រវត្តិរូប។ ដោយសំណាងល្អដែរ ខ្ញុំអត់មានគ្រោះថ្នាក់ដល់ស្លាប់ជីវិត ត្រូវបានចេញពីមន្ទីរឃុំឃាំងហ្នឹង ធ្វើដំណើរតាមផ្លូវទៀត ជម្លៀសចេញពីខេត្តកំពង់ចាមមកដល់តាកែវ។

[១៣:៥២:១៩]

ពេលមកដល់ខេត្តតាកែវនេះ ខ្ញុំបានជួបសាច់ឈាមបងប្អូនខ្ញុំ។ នៅពេលនោះ អ៊ំស្រីខ្ញុំឈ្មោះ យុន បានមកប្រាប់ក្មួយអើយ អន្ទិតណាត ធ្វើប៉េអឹម ហើយនិង អន្ទិតហ៊ឹម ធ្វើទាហានកងម៉ារីនជើងទឹកនៅជ្រោយចង្វាហ្នឹងត្រូវពួកខ្មែរក្រហមយកទៅបាត់ហើយ។ អ៊ីចឹងបងជីដូនមួយប្រុសពីរត្រូវស្លាប់បាត់។ ហើយគាត់ខ្សឹបៗប្រាប់ថា ក្មួយឯងធ្វើប៉ូលិសអ៊ីចឹង ក្មួយឯងកុំនិយាយអីឲ្យសោះប្រយ័ត្នដូច អន្ទិតណាត ហើយនិង អន្ទិតហ៊ឹម ទៅបាត់ទៀត។ ក្មួយឯងថាសិស្សៗ ហើយបួសហ្នឹងទៅ។ ហ្នឹងខ្ញុំក៏និយាយតាមអ៊ំខ្ញុំ។ ស្អែកឡើងមានអ៊ំស្រីរបស់ខ្ញុំម្នាក់ទៀតឈ្មោះ អ៊ំគង់ គាត់បានជូនខ្ញុំឲ្យទៅជួបនឹងឪពុកម្ដាយខ្ញុំនៅជិតមន្ទីរឧក្រិដ្ឋកម្មភូមិតាមាន់ ស្រុកអង្គរជ័យ ខេត្តកំពត។ នៅទីនោះ មេភូមិរបស់ខ្មែរក្រហមហ្នឹងបានមកឆែកឆេរខ្ញុំ មើលទាំងពីសម្លៀកបំពាកសព្វបែបយ៉ាង។ អ៊ីចឹងកាលហ្នឹងខ្ញុំមានប្រាក់កាសសម័យ លន់នល់ ខ្លះ។ ហើយគេឆែកទៅ ខ្ញុំឃើញថាខ្ញុំមានតែកាតសិស្ស សិស្សថ្នាក់ទី៣។ បាទ កាតថ្នាក់ទីបញ្ចប់នោះ ខ្ញុំបោះចោលបាត់ហើយ នៅសល់ថ្នាក់ទី៣ និងកាតប៉ូលិសក៏បោះចោលបាត់ដែរ។ អ៊ីចឹងគេមិនធ្វើអីទេ ប៉ុន្តែយប់ឡើង ពេលយប់ឡើង ខ្ញុំដេកនៅក្រោមគ្រែហ្នឹង មានឈ្លបនៅព្រៃចេកក្បែរផ្ទះហ្នឹងមានកងទ័ពឈ្លបគេមកយាមខ្ញុំ មកឈ្លបយកព័ត៌មានខ្ញុំ ព្រោះខ្ញុំមកពីភ្នំពេញ។ អ៊ីចឹងកន្លែងហ្នឹង ខ្ញុំភ័យ ខ្ញុំព្រួយខ្ញុំខ្លាចខ្លាំងណាស់។ យប់ឡើងម្ដាយ ពេលថ្ងៃម្ដាយខ្ញុំខ្សឹបថា កូនឯងដេកកុំនិយាយអី ខ្លាចគេយកកូនឯងចូលមន្ទីរតាមាន់។ ប៉ុន្តែខ្ញុំសូមជម្រាបបន្តិច មន្ទីរតាមាន់នោះ កាលខ្ញុំទីនោះ ខ្ញុំនៅជិតទីនោះកន្លះខែ ខ្ញុំឃើញអ្នកពីភ្នំពេញ គឺអ្នកថ្មីហ្នឹងចូលទៅក្នុងមន្ទីរតាមាន់ ទៅកើតហ្នឹង គឺបាត់ទៅរហូត មិនដែលឃើញមកវិញទេ ទាំងហ្វូងៗ ច្រើនណាស់។

[១៣:៥៥:២៦]

ដល់ក្រោយមកទៀត គេចេះតែតាមដានខ្ញុំ រុករកខ្ញុំ ចង់សម្លាប់ខ្ញុំចោល ព្រោះខ្ញុំជាមនុស្សពីភ្នំពេញ ប៉ុន្តែគេអត់ដឹងអត្តសញ្ញាណខ្ញុំជាប៉ូលិសទេ គេចេះតែតាមដានមិនឈប់ អ៊ីចឹងមានបងប្រុសម្នាក់ជាអ្នកភូមិនៅទីនោះ បានប្រាប់ឪពុកម្ដាយខ្ញុំថានាំកូនចេញពីកន្លែងហ្នឹងទៅ ទៅស្រុកកំណើតយើងវិញទៅ បើមិនទៅស្រុកកំណើតយើងវិញទេ គេសម្លាប់ចោលមួយពូជហើយ ព្រោះមានកូនមកពីភ្នំពេញ។ អ៊ីចឹងខ្ញុំបញ្ជាក់ថាឪពុកម្ដាយខ្ញុំ ត្រូវខ្មែរក្រហមកៀរមកនៅជិតមន្ទីរតាមាន់ហ្នឹង។ អ៊ីចឹងគាត់ជាអ្នកត្រៀមដែរ ដល់ពេលខ្ញុំហ្នឹង ប្រវត្តិរូបគាត់ត្រូវធ្លាក់ចុះ។

ក្រោយមក ខ្ញុំត្រូវខ្មែរក្រហមហ្នឹងក៏គេឲ្យខ្ញុំចេញពីមន្ទីរតាមាន់ហ្នឹង មកនៅភូមិឡអាចម៍ស្វាហ្នឹង

ក្នុងនៅក្នុងខេត្តកំពតដែរ ព្រំប្រទល់ខេត្តកំពតតាកែវ។ នៅទីនោះៗ គេបានដកសៀវភៅប៊ិកដែលខ្ញុំនៅសេសសល់ហ្នឹង យកអស់ហើយ។ គេថាបន្តិចទៀត គេឲ្យខ្ញុំទៅរៀនហើយ ខ្ញុំឮទៅរៀនភ័យណាស់ព្រោះរៀនគេហ្នឹង ដឹងតែស្លាប់ហើយ។ ក្រោយមក ខ្ញុំបានទៅរស់នៅមកជិតខេត្តតាកែវនេះ មកស្រុកភូមិហើយ។ ខ្ញុំបានរស់នៅកងចល័ត។ នៅកងចល័តហ្នឹង ភាព គេគ្មានឲ្យបាយឲ្យទឹកអីហូបគ្រប់គ្រាន់ទេ បានតែបបរបន្តិចបន្តួច ហើយពេលទំនេរអ៊ីចឹងទៅ ខ្ញុំដើរដកដើមព្រលិត ដើមអីហ្នឹងហូបៗទៅៗ ហូបព្រលិត ហូបក្តាម ហូបខ្យងអីហ្នឹងទៅៗ គ្មានចម្អិនទេ។ រួចហើយ អាហ្នឹងនៅកងចល័តឃុំ ចូលពីកងចល័តឃុំហ្នឹង យើងដើរក្នុងឃុំហ្នឹង រៀបចំដើរធ្វើ ប៉ុន្តែគ្មានអ្វីហូបទេ គឺធ្លាក់ខ្លួនស្គមស្គាំង មានតែស្បែក ហើយនិងឆ្អឹង ហើយសុខភាពក៏ទ្រោមចុះ។ ខ្ញុំគ្រុន គ្រុនហ្នឹងមកដេកពេទ្យ ពេទ្យឃុំហ្នឹងគេ ពេទ្យឃុំហ្នឹងឲ្យតែថ្នាំធ្វើដោយជំឡូងមីហ្នឹងហូបទៅ។ ក៏ប៉ុន្តែម្តាយខ្ញុំ គាត់មានសល់មាសបន្តិចបន្តួច យកទៅដូរថ្នាំ មិនដឹងបានពីណាមក ឲ្យខ្ញុំលេប ខ្ញុំផឹកហ្នឹងបានជាទៅ។

[១៣:៥៨:៣៨]

ក្រោយមកក៏គេបញ្ជូនខ្ញុំទៅកងចល័តស្រុក១០៧ហ្នឹង។ នៅក្នុងកងចល័តហ្នឹង ខ្ញុំធ្វើ ស្គមស្គាំង ហើយ ប៉ុន្តែគេឲ្យខ្ញុំនៅកងពិសេស។ កងពិសេសហ្នឹង គេធ្វើបង្គីហ្នឹង បើយើងគិតជាដី ប្រហែលជិត៣០ ៤០គីឡូដែរ មួយខាងហ្នឹង។ បើខ្ញុំមិនប្រឹងរែកទេ ប្រឹងធ្វើទេ ខ្ញុំហ្នឹងក៏មានបញ្ហា គេយកទៅអប់រំ។ អ៊ីចឹងខ្ញុំប្រឹងរែងទាំងហើមជើងផង អីផង ខ្វះអាហារហូបផង ចេះតែប្រឹងធ្វើទៅ។ ប៉ុន្តែយើងខ្ញុំមិនបានរត់លឿនដូចគេទេ រែកដើរយឺតៗ ចេះតែធ្វើអ៊ីចឹងទៅ។

ក្រោយមកប្រធានកងឈ្មោះ វង់ ដែលនៅក្នុងភូមិហ្នឹង ក្នុងឃុំរនាមហ្នឹងបានប្រធានកង ពុតហ្នឹងបានឲ្យ វង់ ហ្នឹងមកតាមដានខ្ញុំដល់ឪពុកម្តាយខ្ញុំ។ ឪពុកម្តាយខ្ញុំបានមកដល់ហ្នឹង សួរច្រើនដងថាកូនធ្វើអីៗថា កូនខ្ញុំមានតែបួសហើយនិងរៀនទេ។ ក្រោយមកគាត់យកសញ្ញាបត្រដែលខ្ញុំមានហើយនិងកាតអីដែលសេសសល់ខ្ញុំទុកហ្នឹងគាត់យកទៅដុតចោលអត់ទៅ គ្មានទុកនៅទេ ព្រោះខ្លាចគេមកសួរ។ អ៊ីចឹងម្តាយខ្ញុំថា ពេលគេមកដល់ហ្នឹងគាត់ដាំថ្នាំបាន គាត់ដាំថ្នាំហ្នឹងឲ្យទៅប្រធានកង វង់ ហ្នឹងប្រហែលជា ១គីឡូថ្នាំជក់ ហើយនិងមាស។ មាសមិនដឹងប៉ុន្មានគាត់ឲ្យទៅប្រធានកងហ្នឹង ព្រោះគេមកសួរពីរឿងខ្ញុំមកធ្វើប៉ូលិសៗ។ ម្តាយខ្ញុំថាអត់ដែលធ្វើទេ កូនខ្ញុំដឹងតែបួសទៅរៀនទេ។ ក្រោយមកគេបានចាត់ខ្ញុំនៅខាងកើតទីក្រុងតាកែវ ទៅនៅពេលនោះគេមានភួយ គេមានអីចែកឲ្យខ្ញុំដេកគ្រប់គ្នា គេដកភួយចេញពីខ្ញុំបាត់អស់។ ខ្ញុំភ័យដែរ ដកភួយហ្នឹងក៏ខ្ញុំមិនឮមាត់ឮក ខ្ញុំនៅតែធ្វើការជាធម្មតាទៅ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:០១:១៣]

កាលហ្នឹងខ្លួនខ្ញុំក៏នៅតែស្គមអ៊ីចឹង ចេះតែធ្វើអត់តវ៉ាអីជាមួយនឹងមេកងទេ។ ដល់មកដល់ឆ្នាំ៧៨ ក្នុងខែប្រហែលជាខែ៤ហ្នឹងបានប្រធានកង រី ហ្នឹងហៅខ្ញុំសួរពីរឿងអាពាហ៍ពិពាហ៍ឲ្យខ្ញុំរៀបការហ្នឹង។ ហើយនិងអាហ្នឹងបានរាយការណ៍ជូនមកហើយ ព្រោះខ្ញុំ អាពាហ៍ពិពាហ៍នេះខ្ញុំសោកស្ដាយបំផុតលោកប្រធាន។ សោកស្ដាយត្រង់ថា គូដណ្ដឹងរបស់ខ្ញុំហ្នឹងត្រូវបានគ្នាជាប្ដីប្រពន្ធទៅអនាគត ហើយមិនបានគ្នាដូចជាផ្លែឈើកំពុងតែពេញហើយ បេះដាច់មិតមកដូចផ្លែស្វាយស្រក់ជ័រ អាខ្ញុំពេលហ្នឹងនៅប្រធានកងហ្នឹងផ្ដាច់មនោសញ្ចេតនាខ្ញុំ ហើយខ្ញុំគ្មានសិទ្ធិតវ៉ាអី មានតែចុកទ្រូង ចុកថ្លើម ពិបាកក្នុងចិត្ត។ សព្វថ្ងៃឲ្យតែនឹកឃើញរឿងហ្នឹង ខ្ញុំដូចថាវាហួសចិត្តតែម្ដង។ ខ្ញុំនឹកថាកើតមកវាជាតិនេះ ហើយចំសម័យអីវេទនាខ្លាំងម្ល៉េះ រយៈពេលប៉ុន្មានឆ្នាំ ប៉ុន្មានខែ រហូតមកដល់ពេលត្រូវបានគ្នាហើយអត់បានគ្នា គឺថាវាងគ្នា។ អ៊ីចឹងការស្រឡាញ់របស់ខ្ញុំធំធេងណាស់លោកប្រធាន។ ខ្ញុំបានដើរលេងជាមួយគ្នា ហូបចុកជាមួយគ្នា ទៅបុណ្យជាមួយគ្នា កាន់លុយចូលបុណ្យជាមួយគ្នា និងអ្វីផ្សេងៗច្រើនណាស់ អនុស្សាវរីយរបស់ខ្ញុំវាមានជាលក្ខណៈមួយដល់ល្អសម្រាប់គូដណ្ដឹងរបស់ខ្ញុំ ប៉ុន្តែដល់អត់បាន។ ឥឡូវនេះគឺថា ខ្ញុំមានគ្រួសារហើយ ក៏ប៉ុន្តែនឹកនៅស្ដាយ ចុះហេតុអ្វីបានជាគេធ្វើបាបខ្ញុំម្ល៉េះ។ អស់ពីខ្ញុំរៀបអាពាហ៍ពិពាហ៍ហើយ ក៏មិនបានស្រឡាញ់គ្នាទៀត។ រយៈពេលបានប្រហែលជាមួយខែក្រោយមកទៀត លោកឪពុកខ្ញុំគាត់មានជំងឺជាទម្ងន់ ឈឺ ត្រូវពួកកម្មាភិបាលខ្មែរក្រហមហ្នឹងដឹកឪពុកខ្ញុំទៅមន្ទីរពេទ្យនៅឃុំសំបួរ អាហ្នឹងក្នុងស្រុកទ្រាំងដែរ អាហ្នឹងពេទ្យស្រុកគេ។ ទៅដល់ឪពុកខ្ញុំហើមគាត់មានជំងឺអ៊ីចឹង គាត់ស្រែកឃ្លាន គាត់ហេវ គាត់ហត់។ អ៊ីចឹងពេទ្យហ្នឹងគេបូមទឹកពាង បូមទឹកធម្មតាហ្នឹង។ ឃើញថាឪពុកខ្ញុំអស់កម្លាំងៗ គាត់វិលមុខអស់កម្លាំង គាត់ប្រាប់ពេទ្យអើយអស់កម្លាំង គេបូមទឹកហើយចាក់ថ្នាំឲ្យទៅ។ ឪពុកខ្ញុំទៅប្រកាច់លើគេហ្នឹងចេញអាចម៍ពេញគ្រែ ស្លាប់តែម្ដងទៅ។ នេះជាភាពមួយទៀតដែលធ្វើឲ្យនៅក្នុងខួរក្បាលខ្ញុំអាណិតលោកឪពុកខ្ញុំ។ អ៊ីចឹងខ្ញុំមួយជីវិតខ្ញុំមានឪពុកតែមួយ ដល់ឪពុកស្លាប់បាត់ហើយ ទៅឃើញផ្នូរគាត់ ទៅពូនផ្នូរឲ្យគាត់ហើយអស់ហើយ។ ក្រោយមកទៀត ម្ដាយមីងឡើងពីស្ទួងមក ដួលស្លាប់ទៀត។ ហើយមាមួយទៀត គេចោទថាគាត់ធ្វើទាហាន គេយកទៅវាយចោលបាត់ហើយ។ អ៊ីចឹងថា លោកប្រធានអើយ ការសោកស្ដាយរបស់ខ្ញុំវាច្រើនណាស់ ធ្វើម៉េច។

[១៤:០៥:៣២]

អ៊ីចឹងបានថា របបនេះ សូមលោកប្រធានធ្វើយ៉ាងម៉េច កុំឲ្យរបបហ្នឹងកើតមានតទៅទៀត។ ខ្ញុំ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយខ្ញុំកើតក្នុងមួយជីវិតនេះ គឺជាជីវិតអភ័ព្វ ជីវិតគ្មានសេរីភាព។ ដល់ចាស់ហើយ បានមានសេរីភាពបន្តិចបន្តួច ជ្រុលទៅហើយ។ បានថាកើតមួយជីវិតនេះ ស្គាយភាពវេទនា ស្គាយភាពទុក្ខសោកអស់មួយជីវិតតែម្តង។ ខ្ញុំមានប៉ុណ្ណឹង សុំចប់ហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកដើមបណ្តឹងរដ្ឋប្បវេណីមានសំណួរអីទេ?

**2-TCCP-232៖**

សំណួរទី១ ខ្ញុំបាទសុំសួរថា មេធាវីដឹកនាំខ្មែរក្រហមហ្នឹង គឺខ្ញុំនិយាយតាំងពីប្រធានកង រហូតដល់ថ្នាក់ធំៗទាំងអស់។ មេដឹកនាំខ្មែរក្រហម អាចជ្រើសរើសដៃគូជីវិតបាន ចុះហេតុអ្វីបានជាប្រជាជនមិនអាចជ្រើសរើសគូស្រករបានដូចគ្នា សំណួរទី១។ សំណួរទី២ ហេតុអ្វីអង្គការមិនឲ្យខ្ញុំរៀបការជាមួយគូដណ្តឹងរបស់ខ្ញុំ ព្រោះនាងគ្មានកំហុស អ្នកខុសនឹងអង្គការ គឺជាបងប្រុសរបស់នាងទេ ហេតុអ្វី? មានតែសំណួរតែពីរហ្នឹងទេ លោកប្រធាន។

[១៤:០៧:៣៣]

**ប្រធានអង្គជំនុំ៖**

អរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះសូមជម្រាបលោកថា រហូតមកដល់ពេលនេះ ជនជាប់ចោទទាំងពីររូបនៅតែអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ ហេតុដូច្នេះសូមលោកជ្រាប។ សវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-232 ដល់ទីបញ្ចប់ហើយ។ អង្គជំនុំជម្រះអរ-គុណលោក ដែលបានចំណាយពេលវេលាមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី លោកអាចត្រឡប់ទៅវិញបានហើយ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្តឹងរូបនេះ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ សូមអញ្ជើញ!

សូមអញ្ជើញលោកចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

នេះ ដើម្បីធានា<ដល់សហព្រះរាជអាជ្ញា>ថាយើងពិភាក្សាគ្នាពីបញ្ហាដែលសហព្រះរាជអាជ្ញាបានលើកឡើង។ <យើងនឹងពិនិត្យមើលឡើងវិញលើសេចក្តីសម្រេចនៃ>ឯកសារ <D309/6>

<ហើយនឹងជូនដំណឹងដល់លោកនៅពេលសមស្រប។> បើយើងយល់<>មិនច្រឡំទេ គឺថា<លោក> ស្នើសុំឲ្យ<ធ្វើមិនដឹងមិនឮចំពោះ>វិធានការមួយចំនួនដែល<>ដាក់ចេញដោយសហចៅក្រមស៊ើបអង្កេត <ដោយផ្តល់ហេតុផលថា វាគ្មានមូលដ្ឋានក្នុង>វិធានការការពារ ឬក៏<គ្មាន>ហេតុផលណាជាក់លាក់ ដែលពាក់ព័ន្ធទៅនឹងសុចរិតភាពនៃការស៊ើបសួរ។ តើខ្ញុំសង្ខេបបានត្រឹមត្រូវដែរឬទេ លោកព្រះរាជអាជ្ញា?

**លោក នីកូឡាស គូមជែន៖**

ខ្ញុំមិនប្រើពាក្យថា "ធ្វើមិនដឹងមិនឮ" នោះទេ <ប៉ុន្តែ>ខ្ញុំ<យល់ស្របថា អង្គជំនុំជម្រះសាលាដំបូងគួរតែយកចិត្តទុកដាក់>ឲ្យបានទូលំទូលាយថា <គេផ្តល់>ហេតុ<ផល>ថា <ហេតុអ្វីបានជា>សុចរិតភាពនៃកិច្ចស៊ើបសួរ<អាចត្រូវបានប៉ះពាល់ ឬត្រូវដាក់វិធានការការពារជាចាំបាច់>។ ជា<ថ្មីម្តងទៀត យើងគ្រាន់តែស្នើសុំឲ្យលើកលែងការប្រើ>រហស្សនាម<ចំពោះ>សាក្សី<ណាដែលមិនបានស្នើសុំប្រើរហស្សនាម>។ បើសិនណាជាសាក្សីស្នើសុំ យើងគាំទ្រទៅតាមសំណើសុំសាក្សី សុំឲ្យប្រើរហស្សនាមរបស់គាត់។

[១៤:០៩:៥០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើបញ្ហានេះ ពាក់ព័ន្ធទៅនឹងរហស្សនាមទាំងស្រុងតែម្តងឬ? ពីព្រោះការដាក់បង្ហាញឯកសារនេះវាមានប្រភេទវាបី ហើយនិងវិធានការដែលត្រូវដាក់អមទៅជាមួយទៅតាមការលើកឡើងរបស់សហចៅក្រមស៊ើបអង្កេត។ តើយើងកំពុងតែពិភាក្សាគ្នា<លើផែនការទាំងមូល ឬក៏យើងគ្រាន់តែពិភាក្សា> តែបញ្ហាមួយដែលមានកម្រិតគឺ ពាក់ព័ន្ធទៅនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី <ឬក៏សាក្សី> ដែលត្រូវតែប្រើតែរហស្សនាមនោះឬ?

**លោក នីកូឡាស គូមជែន៖**

សំណើសុំរបស់ខ្ញុំគឺថា នៅពេលដែលអង្គជំនុំជម្រះទទួលបាននូវការអនុញ្ញាត<ឲ្យ>បង្ហាញ<ឯកសារ ដោយ>មានការបញ្ជាក់ពីសហចៅក្រមស៊ើបអង្កេត ដែលថាត្រូវតែប្រើប្រាស់វិធានការការពារ <ឬសវនាការអសាធារណៈ>នោះ គឺ<សូមឲ្យលោក លោកស្រី>ចៅក្រម<ធ្វើការវាយតម្លៃ។ ប្រសិនបើខ្វះហេតុផល ខ្ញុំគិតថា គួរតែបញ្ជាក់ទៅ>សហចៅក្រមស៊ើបអង្កេត <ហើយសួរថា តើគេមានព័ត៌មានបន្ថែមទៀតទេ ដែលពួកគេអាចផ្តល់ឲ្យ ពាក់ព័ន្ធទៅនឹងមូលហេតុដែលគេ>យល់ឃើញថា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

វិធានការ<ការពារ គឺមានការ>ចាំបាច់<នោះ។> ប៉ុន្តែបើមិនមានហេតុផលសម្រាប់វិធានការការពារ ឬក៏បើសវនាការអសាធារណៈនោះទេ <ជំហររបស់យើង>គឺថា <>ច្បាប់តម្រូវឱ្យអង្គជំនុំជម្រះបើកសវនាការជាសាធារណៈ ហើយជនជាប់ចោទក៏ត្រូវតែមានសិទ្ធិមួយទទួលបានការជំនុំជម្រះ ជាសាធារណៈដែរ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<យើងមិនធ្លាប់មានករណីមួយណា ដែលយើងឈប់ធ្វើសវនាការសាធារណៈនោះទេ។>

[១៤:១១:១៨]

**លោក នីកូឡាស គូមជែន៖**

ត្រឹមត្រូវហើយលោកស្រីចៅក្រម។ ដូចលោកស្រីបានជ្រាបហើយគឺថា យើងមានសវនាការអសាធារណៈមួយ។ តើអនុញ្ញាតឱ្យខ្ញុំនិយាយចំណុចនេះទេ? ហើយយើងឃើញថាប្រតិចារឹកហ្នឹងក៏ត្រូវបានមានការកោសលុប ហើយផ្សព្វផ្សាយជាសាធារណៈក្រោយមក។ ខ្ញុំ<អាចភ្លេចចំណុចមួយចំនួន ប៉ុន្តែខ្ញុំមើលមិន>ឃើញថា យើង<>ទទួលបានផលប្រយោជន៍អ្វីពីរឿងនេះទេ <ក្រៅពីការធ្វើឱ្យ> សាធារណជន<បាត់បង់ឱកាសក្នុងការស្តាប់ភស្តុតាងសំខាន់>ទៅវិញ<>។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ ហើយសវនាការនឹងបន្តធ្វើនៅចន្ទ ទី២៩ ខែសីហា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃចន្ទ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-219 ឯកាលវិភាគអំពីសវនាការនឹងជូនដំណឹងបន្តិចទៀតនេះ។ សូមភាគីជ្រាប នឹងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់។

បង្គាប់អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.កវិញ និងបង្គាប់ឱ្យនាំខ្លួនគាត់ឱ្យត្រឡប់ចូលរួមសវនាការនៅថ្ងៃចន្ទ ទី២៩ ខែសីហា ឆ្នាំ២០១៦ ឱ្យបានមុនម៉ោង ប្រាំបួនព្រឹក។

សូមអញ្ជើញសម្រាក៕

*(សវនាការផ្អាកនៅម៉ោង ១៤:១២ នាទី)*